ព្រះរាជាណាចក្រកម្ពុជា

ជាត សាសនា ព្រះមហាក្សត្រ

# យុទ្ធសាស្ត្រជាតិ

# ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

## មាតិកា


បុព្វកថា ........ iv

សេចក្តីថ្លែងអំណរគុណ ........ vi

I. ទិដ្ឋភាពរួមនៃយុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ...... ១
 ១. .. ចក្ខុវិស័យ ........ ១
 ២. បេសកកម្ម ........ ១
 ៣. គោលបំណងនៃយុទ្ធសាស្ត្រជាតិ ........ ១

II. សេចក្តីផ្តើម ........ ៣

III. ប្រវត្តិនៃការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ........ ៦

IV. ស្ថានភាពបច្ចុប្បន្ន ........ ១០

V. យុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៣-២០១៧ ........ ១២
 ១. ផែនការយុទ្ធសាស្ត្រទី ១ ៖ ការងារគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ........ ១៣
  ១.១. បញ្ហាប្រឈម ........ ១៣
  ១.២. គោលបំណង ........ ១៣
  ១.៣. វិធានការ ........ ១៤
  ១.៤. ភាគីពាក់ព័ន្ធ ........ ១៥
 ២. ផែនការយុទ្ធសាស្ត្រទី ២ ៖ ការវាយតម្លៃលើការគំរាមកំហែងនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ........ ១៥
  ២.១. បញ្ហាប្រឈម ........ ១៥
  ២.២. គោលបំណង ........ ១៦
  ២.៣. វិធានការ ........ ១៦
  ២.៤. ភាគីពាក់ព័ន្ធ ........ ១៨
 ៣. ផែនការយុទ្ធសាស្ត្រទី ៣ ៖ ការកសាងសមត្ថភាពរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ........ ១៩
  ៣.១. បញ្ហាប្រឈម ........ ១៩
  ៣.២. គោលបំណង ........ ២០

៣.៣. វិធានការ ........ ២១
៣.៤. ភាគីពាក់ព័ន្ធ ........ ២២
៤. ផែនការយុទ្ធសាស្ត្រទី ៤ ៖ ការធ្វើសុខដុមរមនីយកម្មច្បាប់ និងការបង្កើតនីតិវិធីបទប្បញ្ញត្តិច្បាស់លាស់ ........ ២៣
៤.១. បញ្ហាប្រឈម ........ ២៣
៤.២. គោលបំណង ........ ២៤
៤.៣. វិធានការ ........ ២៤
៤.៤. ភាគីពាក់ព័ន្ធ ........ ២៦
៥. ផែនការយុទ្ធសាស្ត្រទី ៥ ៖ ការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងប្រទេស ........ ២៦
៥.១. បញ្ហាប្រឈម ........ ២៦
៥.២. គោលបំណង ........ ២៦
៥.៣. វិធានការ ........ ២៧
៥.៤. ភាគីពាក់ព័ន្ធ ........ ២៩
៦. ផែនការយុទ្ធសាស្ត្រទី ៦ ៖ ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ........ ២៨
៦.១. បញ្ហាប្រឈម ........ ២៨
៦.២. គោលបំណង ........ ២៨
៦.៣. វិធានការ ........ ២៩
៦.៤. ភាគីពាក់ព័ន្ធ ........ ២៩
៧. ផែនការយុទ្ធសាស្ត្រទី ៧៖ការបង្កើនការយល់ដឹងអំពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មសម្រាប់បុគ្គលរាយការណ៍ ........ ៣០
៧.១. បញ្ហាប្រឈម ........ ៣០
៧.២. គោលបំណង ........ ៣០
៧.៣. វិធានការ ........ ៣០
៧.៤. ភាគីពាក់ព័ន្ធ ........ ៣១
VI. ការអនុវត្តការរាយការណ៍និងបញ្ហាប្រឈម ........ ៣២
១. ការអនុវត្ត ........ ៣២
២. ការរាយការណ៍ ........ ៣២
៣. បញ្ហាប្រឈម ........ ៣៣

VII. ឧបសម្ព័ន្ធ ........ ៣៤
១. ឧបសម្ព័ន្ធទី១ ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្រ្តជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ........ ៣៤
IIX. ពាក្យកាត់ ........ ៣៤

# មុខកថា

ការសម្អាតប្រាក់ជាសកម្មភាពទាំងឡាយដែលប្រែក្លាយទ្រព្យសម្បត្តិជាផលនៃបទល្មើស ទៅជាទ្រព្យសម្បត្តិស្របច្បាប់ ក្រោមរូបភាពជាការបំប្លែងឬការផ្ទេរ ការបិទបាំងឬការក្លែងសភាវៈពិត ការធ្វើលទ្ធកម្ម ការកាន់កាប់ឬការប្រើប្រាស់ ដោយប្រើប្រាស់ប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ប្រព័ន្ធជួញដូរមូលបត្រ ក្រុមហ៊ុនអាជីវកម្មស្របច្បាប់ និងវិជ្ជាជីវៈពិសេសផ្សេងៗ ។ សកម្មភាពនេះបានរីករាលដាល និងជះឥទ្ធិពលជាអវិជ្ជមានដល់សេដ្ឋកិច្ចជាតិ តំបន់ និងសកលលោក ។ តាមរបាយការណ៍ស្រាវជ្រាវរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) មូលនិធិដែលត្រូវបានយកមកសម្អាតនៅលើសកលលោក ទទួលបានក្រោមរូបភាពផ្សេងៗ ដូចជា ការជួញដូរមនុស្ស ការជួញដូរគ្រឿងញៀន អំពើពុករលួយ ការក្លែងបន្លំ និងការចាប់ជំរិត ជាដើម មានចំនួនប្រហែលពី ៣% ទៅ ៥% នៃផលិតផលក្នុងស្រុកសរុបរបស់សកលលោកក្នុងរយៈពេលមួយឆ្នាំៗ ។ ទន្ទឹមនេះ ព្រឹត្តិការណ៍ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១ នៅសហរដ្ឋអាមេរិក បានឆ្លុះបញ្ចាំងឲ្យឃើញពីការគំរាមកំហែងយ៉ាងខ្លាំងមួយទៀត ដែលជាសកម្មភាពផ្តល់ហិរញ្ញប្បទានដល់ភេរវករ និងអង្គការភេរវកម្មដែលមានអង្គការចាត់តាំងជាខ្សែចង្វាក់ឆ្លងដែន និងមានការគាំទ្រហិរញ្ញវត្ថុពីប្រភពផ្សេងៗ ។

ក្នុងបរិការណ៍នេះ ប្រទេសកម្ពុជា ក៏ដូចជា ប្រទេសជាច្រើនទៀតនៅលើសកលលោកបាន និងកំពុងទទួលរងនូវការគំរាមកំហែង និងឥទ្ធិពលពីសកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម របស់ឧក្រិដ្ឋជន ភេរវករ និងអង្គការភេរវកម្មនានា ។ ដើម្បីធានាឲ្យបាននូវសន្តិសុខនិងសុវត្ថិភាពសង្គម សេចក្តីថ្លៃថ្នូរ ភាពសុខដុមរមនារបស់ប្រជាជន និងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញវិធានការចាំបាច់នានា រួមមាន វិធានការផ្នែកច្បាប់ ការពង្រឹងការអនុវត្តច្បាប់ និងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌជាតិ តំបន់ និងអន្តរជាតិ ។

បន្ថែមលើកិច្ចខិតខំប្រឹងប្រែងខាងលើ រាជរដ្ឋាភិបាលកម្ពុជាក៏បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការកំណត់គោលដៅជាក់លាក់និងជាយុទ្ធសាស្ត្រ តាមរយៈការបង្កើតផែនការយុទ្ធសាស្ត្រជាតិមួយ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងគ្របដណ្តប់លើទិដ្ឋភាពទាំងអស់ ។ ស្ថិតក្រោមទស្សនវិស័យនេះ យុទ្ធសាស្ត្រជាតិ ៥ឆ្នាំ ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម សម្រាប់រយៈពេលពី

ឆ្នាំ២០១៣ ដល់ ឆ្នាំ២០១៧ ត្រូវបានរៀបចំឡើង ក្នុងគោលបំណងពង្រឹងយន្តការអនុវត្តការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឲ្យកាន់តែមានប្រសិទ្ធភាព និងស្របតាមបទដ្ឋានអន្តរជាតិ ។

យុទ្ធសាស្ត្រជាតិនេះត្រូវបានរៀបចំឡើង ដោយមានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធទាំងអស់ និងបានបញ្ចូលផែនការសកម្មភាពតាមដំណាក់កាល ដោយមានការកំណត់ពេលវេលា និងវិធានការច្បាស់លាស់ ស្របតាមការអនុវត្តការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មជាសកល ។

កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងវិស័យសាធារណៈ និងឯកជនជាកត្តាគន្លឹះ ដើម្បីឲ្យការអនុវត្តយុទ្ធសាស្ត្រជាតិនេះទទួលបានជោគជ័យ និងអាចទប់ស្កាត់សកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៅកម្ពុជាប្រកបដោយប្រសិទ្ធភាព ។

*រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ**
**ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម**

# សេចក្តីថ្លែងអំណរគុណ

រាជរដ្ឋាភិបាលកម្ពុជា សូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានសហការរៀបចំឯកសារ "យុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៣-២០១៧" ។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជា ក៏សូមថ្លែងអំណរគុណផងដែរ ចំពោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ គណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម គណៈកម្មការមូលបត្រកម្ពុជា ក្រុមការងារបច្ចេកទេស លេខាធិការដ្ឋានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ដែលបានខិតខំប្រឹងប្រែងរួមចំណែកក្នុងការរៀបចំយុទ្ធសាស្ត្រជាតិនេះ ប្រកបដោយជោគជ័យ ។

# I. ទិដ្ឋភាពរួមនៃយុទ្ធសាស្ត្រជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

## ១. ចក្ខុវិស័យ

យុទ្ធសាស្ត្រជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៣-២០១៧ មានគោលដៅរួមសំដៅអភិវឌ្ឍន៍ប្រព័ន្ធប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងឧក្រិដ្ឋកម្មហិរញ្ញវត្ថុផ្សេងទៀត ដ៏រឹងមាំមួយនៅកម្ពុជា និងមានសមាហរណកម្មនៅក្នុងតំបន់និងអន្តរជាតិ ដើម្បីរួមចំណែកធានាសន្តិសុខសង្គម សុខដុមរមនា សេចក្តីថ្លៃថ្នូរ សមធម៌ និងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

## ២. បេសកកម្ម

យុទ្ធសាស្ត្រជាតិនេះ មានបេសកកម្មចម្បងក្នុងការស្វែងរក ទប់ស្កាត់ និងលុបបំបាត់សកម្មភាពសម្អាតប្រាក់ និងការផ្តល់ហិរញ្ញប្បទានទៅដល់ភេរវករនិងអង្គការភេរវកម្ម ក្នុងប្រទេស តំបន់ និងអន្តរជាតិតាមរយៈការធានាការប្រតិបត្តិតាមច្បាប់និងបទប្បញ្ញត្តិ ការបង្កើតរបាយការណ៍ស៊ើបការណ៍ដែលមានគុណភាពខ្ពស់ ការពង្រឹងការអនុវត្តច្បាប់ និង លើកកម្ពស់កិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ ។

## ៣. គោលបំណងនៃយុទ្ធសាស្ត្រជាតិ

យុទ្ធសាស្ត្រជាតិនេះ មានគោលដៅជាយុទ្ធសាស្ត្រចំនួន ៧ ក្នុងគោលបំណង ដូចខាងក្រោម ៖

- បញ្ឈប់លំហូរទុនមិនស្របច្បាប់ដែលបានពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- រក្សាសុចរិតភាព និងប្រតិបត្តិការរបស់វិស័យហិរញ្ញវត្ថុ
- ពង្រឹងការត្រួតពិនិត្យ និងយន្តការអនុវត្តច្បាប់និងបទប្បញ្ញត្តិ និង
- ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងស្រុកនិងអន្តរជាតិ ។

### ផែនការយុទ្ធសាស្ត្រទី ១ ៖

ដាក់ឲ្យដំណើរការគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មដើម្បីរៀបចំគោលនយោបាយ និងផ្តល់ការណែនាំក្នុងការអភិវឌ្ឍរបបប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មដែលមានប្រសិទ្ធភាព ។

**ផែនការយុទ្ធសាស្ត្រទី ២ ៖**

វាយតម្លៃភាពគំរាមកំហែងនៃសកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៅកម្ពុជា ។

**ផែនការយុទ្ធសាស្ត្រទី ៣ ៖**

បង្កើនសមត្ថភាពរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងពង្រឹងការអនុវត្តមុខងារ-ភារកិច្ច របស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងបុគ្គលរាយការណ៍ ។

**ផែនការយុទ្ធសាស្ត្រទី ៤ ៖**

សុខដុមនីយកម្មច្បាប់ និងការបង្កើតនីតិវិធីស្របតាមបទប្បញ្ញត្តិច្បាស់លាស់សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងមុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុ ដើម្បីរាយការណ៍ប្រតិបត្តិការសង្ស័យ និងប្រតិបត្តិការសាច់ប្រាក់ អនុវត្តវិធានការទប់ស្កាត់សកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម តាមដានការប្រតិបត្តិតាមកាតព្វកិច្ច និងរក្សាឯកសារកត់ត្រាឲ្យបានគ្រប់គ្រាន់ ។

**ផែនការយុទ្ធសាស្ត្រទី ៥ ៖**

ពង្រឹងកិច្ចសហប្រតិបត្តិការ ការសម្របសម្រួល និងសហការរួមគ្នាក្នុងចំណោមភាគីពាក់ព័ន្ធក្នុងស្រុកដើម្បីបង្កើនប្រសិទ្ធភាពប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

**ផែនការយុទ្ធសាស្ត្រទី ៦ ៖**

ពង្រឹងកិច្ចសហប្រតិបត្តិការ ការសម្របសម្រួល និងសហការរួមគ្នាក្នុងតំបន់ និងអន្តរជាតិ ព្រមទាំងចូលជាសមាជិក Egmont Group នៅពេលខាងមុខ ។

**ផែនការយុទ្ធសាស្ត្រទី ៧ ៖**

លើកកម្ពស់ការយល់ដឹងពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម របស់បុគ្គលរាយការណ៍ និងរាល់ភាគីពាក់ព័ន្ធ រួមមាន អង្គភាពរដ្ឋាភិបាល អ្នកតាក់តែងច្បាប់ និងសាធារណជនទូទៅ ។

## II. សេចក្តីផ្តើម

សកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវបានពិភពលោកចាត់ទុកជាអំពើឧក្រិដ្ឋមួយដែលបង្កអសន្តិសុខនិងសណ្តាប់ធ្នាប់សង្គម បំផ្លាញសេចក្តីថ្លៃថ្នូររបស់ប្រជាជន និងជាឧបសគ្គដ៏ចម្បងក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ។ ជារួម ប្រភពមូលនិធិនៃការសម្អាតប្រាក់ទទួលបានមកពីសកម្មភាពល្មើសច្បាប់នានា ដូចជា ការជួញដូរមនុស្សនិងទេសន្តរប្រវេសន៍ ការជួញដូរផ្លូវភេទ ការជួញដូរគ្រឿងញៀន ការជួញដូរអាវុធខុសច្បាប់ អំពើពុករលួយនិងសំណូក ការក្លែងបន្លំ បទល្មើសបរិស្ថាន ការចាប់ជំរិតនិងចំណាប់ខ្មាំង ការរត់ពន្ធ និង បទល្មើសផ្សេងៗទៀត ។ ទន្ទឹមនេះ ការផ្តល់ជាមធ្យោបាយនិងមូលនិធិដល់ភេរវជន និងអង្គការភេរវកម្ម ដើម្បីបម្រើដល់មហិច្ឆិតា និងមនោគមវិជ្ជាជាសកម្មភាពមួយទៀតដែលកំពុងគំរាមកំហែងដល់ស្ថិរភាពសង្គមនិងសេដ្ឋកិច្ចក្នុងពេលបច្ចុប្បន្ន ។

សកម្មភាពទាំងនេះបានរីកដុះដាលយ៉ាងខ្លាំងនៅលើពិភពលោក ស្របពេលដែលវិស័យហិរញ្ញវត្ថុមានការអភិវឌ្ឍយ៉ាងឆាប់រហ័សក្នុងរយៈពេលបីទសវត្សរ៍ចុងក្រោយនេះ ។ វិស័យហិរញ្ញវត្ថុត្រូវបានប្រើប្រាស់ដើម្បីសម្រួលដល់ការបង្វែរ និងបំប្លែងមូលនិធិដែលទទួលបានពីសកម្មភាពខុសច្បាប់និងហិរញ្ញប្បទានភេរវកម្ម ពីតំបន់មួយទៅតំបន់មួយឲ្យប្រព្រឹត្តទៅយ៉ាងឆាប់រហ័ស ។ ទន្ទឹមនេះ ប្រទេសកំពុងអភិវឌ្ឍន៍ដែលមានប្រព័ន្ធហិរញ្ញវត្ថុមិនទាន់មានការអភិវឌ្ឍពេញលេញនៅឡើយ ត្រូវបានឧក្រិដ្ឋជនព្យាយាមប្រើប្រាស់ជាផ្លូវឆ្លងកាត់សម្រាប់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

ប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍មួយដែលមានទំហំសេដ្ឋកិច្ចតូច បើកចំហនិងមានទីតាំងភូមិសាស្ត្រស្ថិតនៅអាស៊ីអាគ្នេយ៍ មានព្រំប្រទល់ជាប់ឈូងសមុទ្រថៃ ព្រះរាជាណាចក្រថៃ សាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ។ នារយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ កម្ពុជាសម្រេចបានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់គួរអោយកត់សម្គាល់ ដែលទ្រទ្រង់ជាចម្បងដោយការ វិនិយោគបរទេស វិស័យវាយនភ័ណ្ឌ វិស័យទេសចរណ៍ និងវិស័យសំណង់ ។ គួបផ្សំនឹងកត្តាស្ថិរភាពនយោបាយនិងលំនឹងម៉ាក្រូសេដ្ឋកិច្ច ប្រព័ន្ធហិរញ្ញវត្ថុបានទទួលការរីកចម្រើនយ៉ាងឆាប់រហ័ស មានសមាហរណកម្មក្នុងតំបន់និងអន្តរជាតិ និងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ។ ស្ថិតក្នុងបរិបទនេះ កម្ពុជាអាចក្លាយជាប្រទេសទទួលរងការគំរាមកំហែងនៃសកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

ឆ្លើយតបនឹងការគំរាមកំហែងខាងលើ រាជរដ្ឋាភិបាលកម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងនឹងសកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម សំដៅធានាឲ្យបាននូវសន្តិសុខសង្គម សេចក្តីថ្លៃថ្នូររបស់ប្រជាជន និងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ។ អនុវត្តតាមស្មារតីនេះ រាជរដ្ឋាភិបាលកម្ពុជា បានផ្តោតកិច្ចខិតខំប្រឹងប្រែងលើការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការទាំងក្នុងក្របខ័ណ្ឌជាតិ តំបន់ និងអន្តរជាតិ ដើម្បីបញ្ចៀសការប្រើប្រាស់ប្រទេសកម្ពុជាជាយានចម្លងសកម្មភាពរបស់ជនឧក្រិដ្ឋ ។ ទន្ទឹមនេះ ក្របខ័ណ្ឌច្បាប់ ស្ថាប័ន និងហេដ្ឋារចនាសម្ព័ន្ធជាតិក្នុងការទប់ស្កាត់ ត្រួតពិនិត្យ និងបង្ក្រាបការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវបានអភិវឌ្ឍន៍ និងពង្រឹងជាបន្តបន្ទាប់ ។

ដើម្បីបន្តពង្រឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មឲ្យកាន់តែមានប្រសិទ្ធភាព រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតយុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មសម្រាប់ឆ្នាំ២០១៣-២០១៧ នេះ ធ្វើជាផែនការគ្រប់ជ្រុងជ្រោយមួយ ដែលដាក់ចេញយុទ្ធសាស្ត្រនានាសំដៅលើកកម្ពស់គុណភាពប្រព័ន្ធសម្រាប់អនុវត្ត និងនិរន្តរភាពនៃវិធានការទប់ស្កាត់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៅប្រទេសកម្ពុជា ។ ឯកសារនេះ កំណត់យ៉ាងច្បាស់នូវគោលដៅអាទិភាព នៃគោលនយោបាយ និងបង្ហាញវិធានការដែលត្រូវអនុវត្តនៅចំពោះមុខ និងនារយៈពេលវែង ។

## ១. គោលបំណង

យុទ្ធសាស្ត្រជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម មានគោលបំណងដូចខាងក្រោម៖

- តាមដាន បង្ការ និងទប់ស្កាត់ឲ្យមានប្រសិទ្ធភាពនូវសកម្មភាពនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ក្នុងប្រតិបត្តិការហិរញ្ញវត្ថុនៃខឿនសេដ្ឋកិច្ចកម្ពុជា
- ពង្រឹងនិងអភិវឌ្ឍក្របខ័ណ្ឌគតិយុត្តិ និងឧបករណ៍សម្រាប់ទប់ស្កាត់និងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៅកម្ពុជា
- រក្សាសុចរិតភាព និងប្រតិបត្តិការហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និង
- បន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌជាតិ តំបន់ និងអន្តរជាតិ ។

## ២. សនិទាន

យុទ្ធសាស្ត្រជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ផ្តោតជាចម្បងទៅលើប្រព័ន្ធហិរញ្ញវត្ថុ ដោយផ្អែកលើការសន្មតថាវិស័យហិរញ្ញវត្ថុជាមធ្យោបាយប្រើប្រាស់ដើម្បីបិទបាំងប្រភពនៃទ្រព្យសកម្មទទួលបានពីផលនៃបទឧក្រិដ្ឋ ឬត្រូវបានប្រើសម្រាប់គាំទ្រសកម្មភាពភេរវកម្ម ។ ទោះជាយ៉ាងណា សកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មគ្របដណ្តប់ទៅលើវិស័យជាច្រើន និងមានភាពស្មុគស្មាញ មិនមានតែក្នុងប្រតិបត្តិការហិរញ្ញវត្ថុប៉ុណ្ណោះទេ ហេតុដូច្នេះ យុទ្ធសាស្ត្រជាតិ ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម សម្រាប់ឆ្នាំ២០១៣-២០១៧ នេះគឺជាយុទ្ធសាស្ត្រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងអនុញ្ញាតឲ្យភាគីពាក់ព័ន្ធសហការស្វែងរក និងទប់ស្កាត់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៅគ្រប់ទិដ្ឋភាព ទាំងសកម្មភាពកើតមាននៅក្នុងប្រទេសកម្ពុជា និងសកម្មភាពឆ្លងដែន ។

## III. ប្រវត្តិនៃការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

ស្របពេលដែលសេដ្ឋកិច្ចពិភពលោកបានរីកចម្រើន ក្នុងរយៈពេលជាង២ទសវត្សរ៍ចុងក្រោយនេះ សកម្មភាពសម្អាតប្រាក់នៅក្រោមទម្រង់ផ្សេងៗក៏បានកើនឡើងផងដែរ ។ តាមការប៉ាន់ស្មានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និង ធនាគារពិភពលោក (WB) ទឹកប្រាក់ប្រមាណ ២.១៧០ ទៅ ៣.៦១០ ពាន់លានដុល្លាអាមេរិក ស្មើនឹង ៣% ទៅ ៥% នៃផលិតផលសរុបពិភពលោក ត្រូវបានលាងសម្អាតជារៀងរាល់ឆ្នាំ ។ ទឹកប្រាក់ដ៏ច្រើន ដែលមិនមានប្រភពច្បាស់លាស់ និងទទួលបានពីសកម្មភាពខុសច្បាប់ បានបង្កនូវផលប៉ះពាល់ជាអវិជ្ជមានជាច្រើនមកលើ សន្តិសុខសង្គម ស្ថិរភាពនយោបាយ និងសេដ្ឋកិច្ច ដោយសារទឹកប្រាក់នេះភាគច្រើនត្រូវបានប្រើប្រាស់សម្រាប់ផ្តល់ហិរញ្ញប្បទានដល់សកម្មភាពភេរវកម្ម ។

បច្ចុប្បន្នការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវបានគេលើកយកមកនិយាយភ្ជាប់គ្នា ហើយសកម្មភាពទាំងនេះបន្តគំរាមកំហែងដល់សុខដុមរមនារបស់សង្គមនិងសេដ្ឋកិច្ច នៅក្នុងប្រទេសនានាទៅលើសកលលោក ។ ប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ប្រព័ន្ធដូញដូរមូលបត្រ ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវបានប្រើប្រាស់ជាមធ្យោបាយចម្បងសម្រាប់សម្អាតប្រាក់និងផ្តល់ហិរញ្ញប្បទានដល់សកម្មភាពភេរវកម្ម ដើម្បីបម្រើដល់មហិច្ឆិតា និងមនោគមន៍វិជ្ជារបស់អង្គការភេរវកម្ម ឬបុគ្គលជ្រុលនិយមមួយចំនួន ។

ក្នុងគោលដៅទប់ស្កាត់ និងប្រឆាំងរាល់បទល្មើសសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ក្រុមការងារហិរញ្ញវត្ថុត្រូវបានបង្កើតឡើងដោយអន្តររដ្ឋាភិបាលនៃក្រុមប្រទេសឧស្សាហកម្មជឿនលឿន G7 នៅឆ្នាំ១៩៨៩ នៅទីក្រុងប៉ារីស ប្រទេសបារាំង ដែលមានភារកិច្ចចេញនូវបទដ្ឋានអន្តរជាតិ និងវិធានការច្បាប់ ។ ក្រុមការងារនេះទទួលខុសត្រូវ ៖ (១) ត្រួតពិនិត្យនិន្នាការនិងបច្ចេកទេស (២) ត្រួតពិនិត្យឡើងវិញនូវវិធានការដែលអនុវត្តនៅកម្រិតជាតិ ឬអន្តរជាតិ និង (៣) បង្កើតវិធានការប្រឆាំងការសម្អាតប្រាក់ ។ បច្ចុប្បន្ន ក្រុមការងារហិរញ្ញវត្ថុមានប្រទេសចំនួន ៣៤ និងអង្គការតំបន់ចំនួន២ ជាសមាជិក និងមានសមាជិកសមាគត មកពីតំបន់ចំនួន ៨ រួមមាន ៖ (១) ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក ស្តីពីការសម្អាតប្រាក់ (APG) (២) ក្រុមការងារហិរញ្ញវត្ថុតំបន់ការ៉ាប៊ៀន (CFTF) (៣) ក្រុមប្រឹក្សាអឺរ៉ុប (CoE) (៤) ក្រុមទ្វីបអឺរ៉ុបនិងអាស៊ីស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម (The Eurasian Group

on Money Laundering and Terrorist Financing) (៥) ក្រុមប្រឆាំងការសម្អាតប្រាក់ប្រចាំតំបន់អាហ្វ្រិកខាងត្បូងនិងខាងកើត (The Eastern and Southern Africa Anti-Money Laundering Group) (៦) ក្រុមការងារហិរញ្ញវត្ថុនៃអាមេរិកខាងត្បូងប្រឆាំងការសម្អាតប្រាក់ (Financial Action Task Force of South America Against Money Laundering) (៧) ក្រុមការងារអន្តររដ្ឋាភិបាលប្រឆាំងការសម្អាតប្រាក់ក្នុងតំបន់អាហ្វ្រិកខាងលិច (Intergovernmental Anti-Money Laudering Group in West Africa) និង (៨) ក្រុមការងារហិរញ្ញវត្ថុប្រចាំតំបន់អាហ្វ្រិកខាងជើងនិងមជ្ឈឹមបូព៌ា (Middle East and North Africa Financial Action Task Force) ។ ផ្អែកលើការទទួលខុសត្រូវនេះ ក្រុមការងារហិរញ្ញវត្ថុបានដាក់ឲ្យប្រើប្រាស់នូវបទដ្ឋានជាសកលក្នុងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម គឺ "អនុសាសន៍ ៤០ របស់ក្រុមការងារហិរញ្ញវត្ថុ" ដើម្បីឲ្យប្រទេសក្នុងសកលលោកយកមកធ្វើជាមូលដ្ឋានក្នុងការអនុវត្តការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

នៅក្នុងឆ្នាំ ១៩៩៥ ក្រោមកិច្ចផ្តួចផ្តើមដោយកិច្ចប្រជុំរបស់ក្រុមអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុដែលបានប្រព្រឹត្តឡើងនៅក្នុងរាជវាំងឈ្មោះ Egmont Arenbeg ក្នុងទីក្រុងប្រ៊ុយសែល ប្រទេសបែលហ្សិក ដែលចូលរួមពីប្រទេសចំនួន២៤ កិច្ចប្រជុំបានបង្កើតក្រុម Egmont ដែលជាក្រុមក្រៅផ្លូវការនៃបណ្តាញអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ដើម្បីស្វែងរកវិធីសាស្ត្រពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការផ្លាស់ប្តូរព័ត៌មាន ការបណ្តុះបណ្តាល និងចែករំលែកបទពិសោធន៍និងជំនាញ ។ ក្រុម Egmont ត្រូវបានគ្រប់គ្រងដោយក្រុមប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ (HoFIUs) មកពីប្រទេសជាសមាជិកទាំងអស់ ។ ក្រុមនេះមានតួនាទីពិនិត្យ និងសម្រេចលើសមាជិកភាព រចនាសម្ព័ន្ធ ថវិកា និងគោលការណ៍របស់ក្រុម Egmont ហើយត្រូវជួបប្រជុំគ្នាម្តងក្នុងមួយឆ្នាំ ។ ក្រុម Egmont មានសមាជិកចំនួន ១២៧ ប្រទេស ដោយបែងចែកជា ៥ តំបន់ធំៗ រួមមាន តំបន់អាមេរិកចំនួន៣២ប្រទេស តំបន់អាហ្វ្រិកចំនួន ១០ ប្រទេស តំបន់អឺរ៉ុបចំនួន៥៥ប្រទេស តំបន់អាស៊ីប៉ាស៊ីហ្វិកចំនួន២១ប្រទេស និងតំបន់អូសេអានីចំនួន ៩ប្រទេស ។

ដើម្បីរួមចំណែកទប់ស្កាត់ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ជាមួយអង្គការស្ថាប័ន និងប្រទេសនានា នៅក្នុងតំបន់ និងសកលលោក រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចចូលជាសមាជិករបស់ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (APG) នៅខែមិថុនា ឆ្នាំ២០០៤ ក្នុង

កិច្ចប្រជុំមហាសន្និបាតនិងវេទិកាជំនួយបច្ចេកទេសលើកទី៧ ប្រចាំឆ្នាំ២០០៤ នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ។ APG ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៧ នៅទីក្រុងបាងកក ប្រទេសថៃ ក្នុងទម្រង់ជាអង្គការអន្តរជាតិស្វយ័ត និងសហការគ្នា ដោយមានមុខងារ ៖ (១) វាយតម្លៃសមាជិករបស់ខ្លួន អំពីការប្រតិបត្តិតាមបទដ្ឋានអន្តរជាតិក្នុងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម (២) សម្របសម្រួលជំនួយបច្ចេកទេសនិងការបណ្តុះបណ្តាល (៣) ចូលរួមនិងសហប្រតិបត្តិការក្នុងបណ្តាញប្រឆាំងការសម្អាតប្រាក់អន្តរជាតិ (៤) ស្រាវជ្រាវនិងវិភាគវិធីសាស្ត្រនិងនិន្នាការនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និង (៥) រួមចំណែកអភិវឌ្ឍន៍គោលនយោបាយជាសកលក្នុងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ បច្ចុប្បន្ន APG មានសមាជិកចំនួន ៤១ ប្រទេស ។

នៅខែកុម្ភៈ ឆ្នាំ២០០៧ ក្រុមបេសកកម្ម APG និងធនាគារពិភពលោក បានមកធ្វើការវាយតម្លៃអញ្ញមញ្ញពីក្របខ័ណ្ឌគតិយុត្តិ និងយន្តការអនុវត្តជាក់ស្តែងនៅកម្ពុជា លើការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នៅពេលដែលកម្ពុជាស្ថិតក្នុងដំណាក់កាលកំពុងអភិវឌ្ឍន៍ ក្របខ័ណ្ឌ គតិយុត្តិនិងយន្តការអនុវត្ត នៅឡើយ ។

ដោយយល់ឃើញពីតម្រូវការចាំបាច់ជាក់ស្តែង និងជាយន្តការសហប្រតិបត្តិការក្នុងការឆ្លើយតបនឹងការប្រឈមនេះ ប្រទេសកម្ពុជា បានដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ក្រមព្រហ្មទណ្ឌ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ក្រមនីតិវិធីព្រហ្មទណ្ឌ នៅថ្ងៃទី៣០ ខែសីហាឆ្នាំ២០០៧ ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ និងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ។ ក្របខ័ណ្ឌគតិយុត្តិទាំងនេះ បានបង្កើតមូលដ្ឋានគ្រឹះសម្រាប់ទប់ស្កាត់និងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

លើសពីនេះ ដើម្បីឈានទៅសម្រេចឲ្យបាននូវគោលដៅទប់ស្កាត់ និងលុបបំបាត់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មឲ្យមានប្រសិទ្ធភាព ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) ធ្វើជាភ្នាក់ងារប្រតិបត្តិច្បាប់នេះ ដែលមាន

សមាសភាពក្រុមប្រឹក្សាភិបាល ជាស្ថាប័នតំណាងមកពី (១) ទីស្តីការគណៈរដ្ឋមន្ត្រី (២) ក្រសួងយុត្តិធម៌ (៣) ក្រសួងមហាផ្ទៃ (៤) ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង (៥) ធនាគារជាតិនៃកម្ពុជា ។

អង្គភាពនេះ មានមុខងារ និងភារកិច្ចសំខាន់ៗ រួមមាន ទទួលរបាយការណ៍ប្រតិបត្តិការសង្ស័យ និងព័ត៌មានផ្សេងៗពីបុគ្គលរាយការណ៍ វិភាគវាយតម្លៃ និងរាយការណ៍បន្តទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីស៊ើបអង្កេត និងសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធក្នុងស្រុកនិងអន្តរជាតិក្នុងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

ទន្ទឹមនេះ ដើម្បីពង្រឹងនិងពង្រីកវិសាលភាពនៃយន្តការអនុវត្តច្បាប់ និងកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១២ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ជាយុត្តាធិការថ្នាក់ជាតិជាន់ខ្ពស់មានលក្ខណៈអចិន្ត្រៃយ៍និងមានវិសាលភាពគ្របដណ្តប់ទូទាំងប្រទេស សម្រាប់ទប់ស្កាត់ និងលុបបំបាត់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ គណៈកម្មាធិការនេះ មានសមាសភាព ៖ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាប្រធាន អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាអនុប្រធានប្រចាំការ តំណាងគណៈកម្មាធិការជាតិប្រឆាំងអំពើភេរវកម្ម ជាអនុប្រធាន ក្រុមប្រឹក្សាភិបាល ស.ហ.ក ទាំងអស់ និងតំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក ។

ក្នុងស្មារតីបន្តពង្រឹងប្រសិទ្ធភាព និងអភិវឌ្ឍប្រព័ន្ធប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម រាជរដ្ឋាភិបាលកម្ពុជាបានបង្កើត "យុទ្ធសាស្ត្រជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម សម្រាប់ឆ្នាំ២០១៣-២០១៧" ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ។ យុទ្ធសាស្ត្រជាតិនេះបានដាក់ចុះនូវវិធានការអនុវត្តនានា សំដៅទប់ស្កាត់ និងលុបបំបាត់សកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម សម្រាប់ជាផលប្រយោជន៍ និងសុខសន្តិភាពរបស់ប្រជាជន និងប្រទេសជាតិ ។ ការអនុវត្តយុទ្ធសាស្ត្រជាតិនេះ តម្រូវឲ្យមានកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួល រវាងស្ថាប័នរដ្ឋាភិបាល គ្រឹះស្ថានហិរញ្ញវត្ថុនិងគ្រឹះស្ថានមិនមែនហិរញ្ញវត្ថុពាក់ព័ន្ធទាំងអស់ និងសាធារណជនទូទៅ ។

## IV. ស្ថានភាពបច្ចុប្បន្ន

បន្ទាប់ពីទទួលបាននូវសន្តិភាពទាំងស្រុងនៅឆ្នាំ ១៩៩៨ មក រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងជាប់ជាប្រចាំក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិសំដៅកាត់បន្ថយភាពក្រីក្រ ។ ជាក់ស្តែង កំណើនសេដ្ឋកិច្ចនារយៈពេល ២ទសវត្សរ៍ចុងក្រោយនេះ គិតជាមធ្យមប្រមាណ ៦,៥ ភាគរយ ហើយអត្រាភាពក្រីក្របានធ្លាក់ចុះជាមធ្យម ១ភាគរយក្នុងមួយឆ្នាំ ។ ទន្ទឹមនឹងនោះ វិស័យធនាគារនិងហិរញ្ញវត្ថុ ក៏មានការរីកចម្រើនយ៉ាងឆាប់រហ័សផងដែរ ទាំងវិសាលភាពនិងទំហំប្រតិបត្តិការ ។ ក្នុងស្ថានភាពរីកចម្រើនទាំងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គួបផ្សំនឹងកម្រិតដុល្លារូបនីយកម្មខ្ពស់នៅកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការប្រយុទ្ធប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការពង្រឹងប្រព័ន្ធប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម តាមរយៈការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយប្រទេសក្នុងតំបន់និងពិភពលោក ការធ្វើឲ្យប្រសើរឡើងនូវក្របខ័ណ្ឌគតិយុត្តិ និងការបង្កើតឲ្យមានយន្តការអនុវត្តច្បាប់ ដូចជា ការដាក់ឲ្យប្រើប្រាស់ច្បាប់គោលនិងសំខាន់ៗ ។ លើសពីនេះ ក្របខ័ណ្ឌស្ថាប័នក៏ត្រូវបានបង្កើតនិងពង្រឹងជាលំដាប់ រួមមាន ការបង្កើតឲ្យមានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងការបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

បច្ចុប្បន្ន អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបាននិងកំពុងទទួលរបាយការណ៍ប្រតិបត្តិការសង្ស័យ និងប្រតិបត្តិការសាច់ប្រាក់ ពីបុគ្គលរាយការណ៍ជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ហើយក្នុងនោះក៏មានករណីមួយចំនួនត្រូវបានបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីស៊ើបអង្កេតបន្តតាមច្បាប់ ។ ជាមួយគ្នានេះ ស.ហ.ក បានពង្រឹងកិច្ចសហប្រតិបត្តិការក្នុងស្រុក តាមរយៈការចុះហត្ថលេខាលើអនុស្សរណៈយល់គ្នាស្តីពីការផ្លាស់ប្តូរព័ត៌មានជាមួយអគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ និងជាមួយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងកិច្ចសហប្រតិបត្តិការក្នុងតំបន់និងអន្តរជាតិតាមរយៈការចុះហត្ថលេខាលក្ខណៈទ្វេភាគីលើអនុស្សរណៈយល់គ្នា ស្តីពីការផ្លាស់ប្តូរព័ត៌មានហិរញ្ញវត្ថុទៅវិញទៅមកជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុប្រទេសម៉ាឡេស៊ី បង់ក្លាដេស ស្រីលង្កា ជប៉ុន និងវៀតណាម ។

ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ផងដែរ ដោយបាននិងកំពុងផ្តល់ការបណ្តុះបណ្តាលអំពីជំនាញ និងបច្ចេកទេសនៃការស៊ើបអង្កេតពាក់ព័ន្ធនឹងការស្វែងរក

ប្រភព ទីតាំង និងការប្រើប្រាស់ មូលនិធិខុសច្បាប់ ជាមួយនឹងការជួយឧបត្ថម្ភ ទាំងធនធានមនុស្ស និងហិរញ្ញវត្ថុ ពីបណ្ដាប្រទេសជាមិត្ត និងអង្គការដៃគូរអន្តរជាតិនានា ។

ជាមួយនឹងសមិទ្ធិផលខាងលើនេះ រាជរដ្ឋាភិបាលក៏នៅតែបន្តការយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងនិន្នាការរីកចម្រើននៃបច្ចេកទេសនិងការគំរាមកំហែងថ្មីៗ នៃសកម្មភាពសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដោយបានផ្ដោតទៅលើ ៖

១. ការពិនិត្យនិងបំពេញបន្ថែមរាល់ចំណុចខ្វះខាត ដែលអាចកើតមាននៅក្នុងក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ ដើម្បីធានាឲ្យការអនុវត្តវិធានការស្វែងរក ទប់ស្កាត់ និងការដាក់ទោសការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឲ្យកាន់តែមានប្រសិទ្ធភាព

២. ការជំរុញកិច្ចដំណើរការនៃគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

៣. ការពង្រឹងការអនុវត្តវិធានការបង្កក ឃាត់ទុក និងរឹបអូសទ្រព្យសម្បត្តិរបស់ឧក្រិដ្ឋជន

៤. ការពង្រឹងសមត្ថភាពរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងភ្នាក់ងារអនុវត្តច្បាប់នានា

៥. ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការក្នុងស្រុក ក្នុងតំបន់ និងអន្តរជាតិ និង

៦. ការលើកកម្ពស់ការយល់ដឹងអំពីការគំរាមកំហែង និងកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដល់អង្គភាព ស្ថាប័នពាក់ព័ន្ធនានា របស់រាជរដ្ឋាភិបាល ក្រុមសង្គមស៊ីវិល និងសាធារណជនទូទៅ ។

## V. យុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ២០១៣-២០១៧

យុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម បានបញ្ចូលគោលការណ៍ យន្តការនិងនិតិវិធីជាក់លាក់សម្រាប់ការកំណត់អាទិភាព និងអនុវត្តតាមស្តង់ដារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់ក្រុមការងារហិរញ្ញវត្ថុឲ្យមានប្រសិទ្ធភាព ។ វិធានការ និងគំនិតផ្តួចផ្តើម គោលនយោបាយនៅក្នុងយុទ្ធសាស្ត្រជាតិនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើភាពងាយរងគ្រោះ និង ធនធានដែលកម្ពុជាមាន ក្នុងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ លើសពីនេះ ផែនការ នៃការអនុវត្តវិធានការ និងគំនិតផ្តួចផ្តើមគោលនយោបាយ ត្រូវបានរៀបចំឡើងជាដំណាក់កាល និងតាម លំដាប់លំដោយស្របតាមអនុសាសន៍របស់ក្រុមការងារហិរញ្ញវត្ថុ (FATF) ។

ស្ថានភាពបច្ចុប្បន្នបានបង្ហាញថា ការអនុវត្តកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទាន ភេរវកម្មនៅមានកម្រិតនៅឡើយ ដោយសារការខ្វះខាតការចូលរួមពីភាគីពាក់ព័ន្ធនានា ។ យុទ្ធសាស្ត្រជាតិ នេះនឹងក្លាយជាឯកសារមួយដ៏សំខាន់ ដើម្បីជួយឲ្យភាគីពាក់ព័ន្ធទាំងអស់យល់អំពីតួនាទី និងការទទួល ខុសត្រូវរបស់ខ្លួនក្នុងការរួមចំណែកប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៅកម្ពុជា ។ អាស្រ័យហេតុនេះ ដើម្បីឲ្យការអនុវត្តវិធានការទប់ស្កាត់ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទាន ភេរវកម្មទទួលបានជោគជ័យ តម្រូវឲ្យមានការចូលរួម និងការប្តេជ្ញាចិត្តពីគ្រប់ភ្នាក់ងារពាក់ព័ន្ធរបស់ រាជរដ្ឋាភិបាល គ្រឹះស្ថានហិរញ្ញវត្ថុ មុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុ និងសាធារណជន ។

យុទ្ធសាស្ត្រជាតិនេះបានដាក់ចេញនូវផែនការសកម្មភាព សម្រាប់ឆ្នាំ២០១៣-២០១៧ ដើម្បីបំពេញ ការខ្វះខាតដែលនៅសេសសល់ក្នុងការអនុវត្តអនុសាសន៍គន្លឹះ និងស្នូលទាំង ១៤ របស់ក្រុមការងារ ហិរញ្ញវត្ថុ ក៏ដូចជាសម្រេចឲ្យបានការប្រតិបត្តិតាមពេញលេញនូវអនុសាសន៍ផ្សេងទៀត ដែលបានលើក ឡើងនៅក្នុងរបាយការណ៍វាយតម្លៃអញ្ញមញ្ញឆ្នាំ២០០៧ ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញា អនុវត្តវិធានការនានានៅក្នុងយុទ្ធសាស្ត្រជាតិនេះ ដើម្បីធ្វើឲ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធប្រឆាំងការ សម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ស្របតាមបទដ្ឋានអន្តរជាតិ ។

## ១. ផែនការយុទ្ធសាស្ត្រទី ១៖ ការងារគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

### ១.១. បញ្ហាប្រឈម

តាមបទពិសោធន៍អន្តរជាតិ ការអនុវត្តក្របខ័ណ្ឌជាតិក្នុងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មប្រកបដោយប្រសិទ្ធភាព តម្រូវឲ្យមានយន្តការសម្របសម្រួល និងសហប្រតិបត្តិការពីសំណាក់ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ។ យន្តការនេះ ក៏នឹងអនុញ្ញាតឲ្យការអនុវត្តគោលនយោបាយជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ស្របជាមួយនឹងគំនិតផ្តួចផ្តើមនានានៅក្នុងតំបន់និងពិភពលោកនិងអាចបំពេញតាមកាតព្វកិច្ចអន្តរជាតិ ។

### ១.២. គោលបំណង

គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវដាក់ឲ្យដំណើរការដើម្បី ៖

- ប្រមូលផ្តុំក្រសួងនិងស្ថាប័នរដ្ឋពាក់ព័ន្ធទាំងអស់ ដែលស្ថិតក្នុងរបបប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- អ្នកចូលរួមទាំងនេះត្រូវទទួលស្គាល់តួនាទីរបស់ខ្លួន និងមានកាតព្វកិច្ចប្រើប្រាស់ធនធានដើម្បីអនុវត្តកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មប្រកបដោយប្រសិទ្ធភាព
- ជំនះរាល់ការលំបាកនៅក្នុងដំណើរការបង្កើតនិងអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម (ដូចជា ការសម្របសម្រួលនិងសហប្រតិបត្តិការក្នុងការចែករំលែកព័ត៌មាន ការបង្កើតសកម្មភាពកែតម្រូវ និងគំនិតផ្តួចផ្តើមអនុវត្ត)
- បង្កើតយុទ្ធសាស្ត្រដែលទូលំទូលាយដោយពិចារណាពីចំណុចខ្សោយរបស់កម្ពុជា ក្នុងការអនុវត្តអនុសាសន៍អន្តរជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- កសាងសមត្ថភាពក្នុងស្រុកក្នុងការរក្សានិរន្តរភាពនៃរបបប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មប្រកបដោយប្រសិទ្ធភាព
- ធានាឯករាជ្យភាពនៃប្រតិបត្តិការ និងការសម្ងាត់នៃការងាររបស់អង្គភាពស៊ើបការហិរញ្ញវត្ថុកម្ពុជា ។

## ១.៣. វិធានការ

- អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រូវបានចុះហត្ថលេខានៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១២ ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលគោលនយោបាយក្នុងចំណោមអាជ្ញាធរមានសមត្ថកិច្ច ។ ការដាក់ឲ្យដំណើរការងាររបស់គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម តាមកម្មវិធីដែលបានឯកភាពសម្រាប់ការប្រជុំកំណត់កម្មវិធីការងារប្រចាំឆ្នាំ និងរយៈពេលមធ្យម ដោយមានរំលេចច្បាស់អំពីធាតុចេញដើម្បីសម្រេចគោលបំណងរួមនៃយុទ្ធសាស្ត្រជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- ត្រូវសម្រេចបញ្ចប់ផែនការសកម្មភាព និងតាមដានការអនុវត្តដើម្បីធានាថាអ្នកចូលរួមនីមួយៗប្រតិបត្តិតាមជំហានសកម្មភាពនៅក្នុងផែនការសកម្មភាព សម្រាប់ការអនុវត្តយុទ្ធសាស្ត្រជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- ត្រូវធ្វើការងារដើម្បីឈានទៅសម្រេចកិច្ចព្រមព្រៀងអំពីការកែប្រែច្បាប់ស្តីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ច្បាប់ស្តីពីការប្រឆាំងអំពើភេរវកម្ម ក្រមព្រហ្មទណ្ឌ និងឧបករណ៍បទប្បញ្ញត្តិផ្សេងទៀតដើម្បីពង្រឹងបទប្បញ្ញត្តិសម្រាប់អនុញ្ញាតឲ្យមានការបង្កកទ្រព្យសកម្ម ការរឹបអូសបត្យាប័ន ជំនួយអញ្ញមញ្ញផ្នែកច្បាប់ ការចែករំលែកព័ត៌មានស្របតាមបទដ្ឋានអន្តរជាតិរបស់ក្រុមការងារហិរញ្ញវត្ថុ និងតម្រូវការរបស់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ
- សម្រេចបញ្ចប់ការសម្គាល់អត្តសញ្ញាណបុគ្គលរាយការណ៍ ទៅតាមតម្រូវការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម រួមមានការពង្រីកការគ្រប់ដណ្តប់ចំពោះធនាគារជាតិនៃកម្ពុជាផង ។ ត្រូវបញ្ជាក់អះអាង តួនាទីរបស់ស្ថាប័នបញ្ញត្តិកម្មក្នុងការត្រួតពិនិត្យបុគ្គលរាយការណ៍ក្នុងផ្នែកហិរញ្ញវត្ថុ និងមុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុ ។ ត្រូវយល់ព្រមជាមួយស្ថាប័នបញ្ញត្តិកម្ម អំពីខ្លឹមសារដែលត្រូវវាយតម្លៃអំពីការប្រតិបត្តិតាមតម្រូវការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ ។ ត្រូវធ្វើការងារដើម្បីបញ្ចូលការវាយតម្លៃអំពីការប្រតិបត្តិតាមការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ក្នុងការត្រួតពិនិត្យជាប្រចាំ/របបវាយតម្លៃរបស់បញ្ញត្តិកររៀងៗខ្លួន ។ ត្រូវអះអាងបញ្ជាក់ ឬបង្កើតទណ្ឌកម្ម របបនិង

យន្តការពង្រឹងការអនុវត្តសម្រាប់តាមដានការអនុវត្តសកម្មភាពកែតម្រូវដាច់ខាតរបស់បុគ្គលរាយការណ៍

- ត្រូវធានាថាមានធនធានគ្រប់គ្រាន់សម្រាប់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ស្ថាប័នបញ្ញត្តិកម្ម ភ្នាក់ងារពង្រឹងការអនុវត្តច្បាប់ ភ្នាក់ងារស៊ើបអង្កេត និងអាជ្ញាធរកាត់ទោស ដើម្បីអនុញ្ញាតឲ្យការអនុវត្តវិធានការទប់ស្កាត់ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មមានប្រសិទ្ធភាព
- ត្រូវតាមដានការអនុវត្តយុទ្ធសាស្ត្រជាតិនិងចាត់វិធានការកែតម្រូវដើម្បីកែតម្រូវការប្រែប្រួល ឬការអភិវឌ្ឍដែលមិនត្រូវបានរំពឹងទុកជាមុន
- ត្រូវតាមដានប្រសិទ្ធភាពនៃការអនុវត្តវិធានការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- ត្រូវរៀបចំរបាយការណ៍ប្រចាំគ្រាអំពីស្ថានភាពនៃក្របខណ្ឌ និងការរីកចម្រើនរបស់ប្រទេសកម្ពុជា ក្នុងការអនុវត្តតម្រូវការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

### ១.៤. ភាគីពាក់ព័ន្ធ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា គណៈកម្មការមូលបត្រកម្ពុជា ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងពាណិជ្ជកម្ម ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ទីស្តីការគណៈរដ្ឋមន្ត្រី ស្ថាប័នអយ្យការ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា អង្គភាពប្រឆាំងអំពើពុករលួយ គណៈកម្មាធិការជាតិប្រឆាំងអំពើភេរវកម្ម អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

## ២. ផែនការយុទ្ធសាស្ត្រទី ២៖ ការវាយតម្លៃពីការគំរាមកំហែងនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

### ២.១. បញ្ហាប្រឈម

សេដ្ឋកិច្ចកម្ពុជាផ្អែកជាខ្លាំងលើសាច់ប្រាក់និងដុល្លារូបនីយកម្ម កម្រិតខ្ពស់នៃវត្តមានសេដ្ឋកិច្ចក្រៅផ្លូវការ ធ្វើឲ្យមានការលំបាក ដើម្បីទទួលបានព័ត៌មានគ្រប់គ្រាន់អំពីសកម្មភាព និងប្រតិបត្តិការហិរញ្ញវត្ថុ ។ ប្រាក់ដុល្លារអាមេរិកជាមធ្យោបាយទូទាត់និងរក្សាតម្លៃត្រូវបានប្រើប្រាស់ច្រើនបំផុត ពិសេសសម្រាប់ប្រតិបត្តិការធំៗ ។ អាទិភាពនៃអ្នកផ្តល់សេវាហិរញ្ញវត្ថុក្រៅផ្លូវការ កង្វះក្របខ័ណ្ឌទូលំទូលាយសម្រាប់ប្រតិបត្តិការអចលនទ្រព្យ វត្តមាននៃអាជីវកម្មផ្ទេរប្រាក់ក្រៅផ្លូវការ និងប្រតិបត្តិការកាស៊ីណូដែលមានការគ្រប់គ្រងតិចតួចបានបង្កឱកាសសម្រាប់ឧក្រិដ្ឋជនរំលោភប្រព័ន្ធនេះ ដើម្បីបម្រើឲ្យសកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ ថ្មីៗនេះ អាជីវកម្មអចលនទ្រព្យមានប្រតិបត្តិការ

រីកសុះសាយ និងទូលំទូលាយត្រូវបានរាយការណ៍មកថាត្រូវបានទូទាត់ជាធម្មតាជាសាច់ប្រាក់ដោយផ្ទាល់រវាងអ្នកទិញនិងអ្នកលក់ទ្រព្យសម្បត្តិ ។

ប្រទេសកម្ពុជាពុំទាន់មានការប៉ាន់ស្មាន និងទិន្នន័យសកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មទេ ។ របាយការណ៍វាយតម្លៃអញ្ញមញ្ញឆ្នាំ២០០៧ បានបង្ហាញច្បាស់ថា ផលនៃបទឧក្រិដ្ឋទទួលបានជាចំបងពីការកេងប្រវ័ញ្ចនិងចរាចរមនុស្ស អំពើពុករលួយ និង ចរាចរគ្រឿងញៀន ។ ការយល់ឃើញជារួមអំពីបច្ចេកទេសសម្អាតប្រាក់នៅកម្ពុជាអាចនិយាយបានថា នៅវិលជុំវិញប្រតិបត្តិការធនាគារ អាជីវកម្មផ្ទេរប្រាក់ក្រៅផ្លូវការ ការដឹកជញ្ជូនសាច់ប្រាក់ឆ្លងដែនមិនស្របច្បាប់ ការវិនិយោគអចលនទ្រព្យ និងការលេងល្បែងកាស៊ីណូ ។ អវត្តមាននៃភស្តុតាងជាក់ស្តែងអំពីសកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម បានអំពាវនាវឲ្យមានការវាយតម្លៃជាផ្លូវការអំពីការគំរាមកំហែងនិងហានិភ័យទាំងនោះ ។

## ២.២. គោលបំណង

ការវាយតម្លៃការគំរាមកំហែងពីការសម្អាតប្រាក់មានគោលបំណងវាស់ទំហំហានិភ័យ និងសកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៅកម្ពុជា ។ ការវាយតម្លៃត្រូវបានសង្ឃឹមថា ជួយអ្នកចេញគោលនយោបាយ បញ្ញត្តិករ និងភ្នាក់ងារពង្រឹងការអនុវត្តច្បាប់ឲ្យយល់កាន់តែច្បាស់ពីវិសាលភាព ឧប្បត្តិហេតុ និងមូលហេតុជាឫសគល់នៃសកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ លទ្ធផលទទួលបានពីការវាយតម្លៃ នឹងជួយណែនាំរាជរដ្ឋាភិបាលឆ្ពោះទៅរកការបញ្ចៀសកំហុសឆ្គងក្នុងក្របខ័ណ្ឌច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដំណើរការរដ្ឋបាល និងជួយដល់ការខិតខំប្រឹងប្រែងកសាងយុទ្ធសាស្ត្ររយៈពេលមធ្យមទៅអនាគត ដើម្បីប្រយុទ្ធប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ ប្រការដែលពាក់ព័ន្ធជាពិសេស គឺជាការងាររបស់រាជរដ្ឋាភិបាលក្នុងការចូលជ្រៅទៅក្នុងផ្នែកហិរញ្ញវត្ថុ ដើម្បីជំរុញឲ្យឃ្លាតឆ្ងាយអំពីការកម្រិតសេដ្ឋកិច្ចដែលផ្អែកលើសាច់ប្រាក់ និងការហាមឃាត់នៃសេដ្ឋកិច្ចដុល្លារូបនីយកម្ម ។

## ២.៣. វិធានការ

ប្រទេសកម្ពុជាត្រូវដឹកនាំការវាយតម្លៃជាផ្លូវការនៃការគំរាមកំហែង និងហានិភ័យនៃសកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នៅដំណាក់កាលទី១នៅថ្នាក់ជាតិស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម តាមរយៈ

ក្រុមការងារអន្តរស្ថាប័នរួមគ្នាមួយ ។ ក្រុមការងារនេះត្រូវសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងនិងបញ្ចូលក្នុងបញ្ជីទេពកោសល្យ មុខជំនាញនិងធនធានដែលបានតម្រូវដើម្បីអនុវត្តការវាយតម្លៃនេះ ។ ក្រុមការងារនេះត្រូវផ្តោតទៅលើ ៖

ក. ការរកឲ្យឃើញហានិភ័យ ការគំរាមកំហែងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឬភាពរងគ្រោះថ្នាក់នៅគ្រប់ផ្នែកពាក់ព័ន្ធទាំងអស់

ខ. ការងារស្រាវជ្រាវនិងអង្កេត បើអាចអនុវត្តបាន ត្រូវផ្តល់លទ្ធផលរកឃើញយ៉ាងទូលំទូលាយនិងគួរឲ្យជឿទុកចិត្តបានអំពីប្រភេទសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងចំនួនទឹកប្រាក់ដែលបានប៉ាន់ស្មាន

គ. ការយកចិត្តទុកដាក់ទៅលើការយល់ដឹង និងគំលាតនៃព័ត៌មាន ក្នុងរបបសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

ឃ. លើកសំណើអនុសាសន៍សម្រាប់ដោះស្រាយការខ្វះខាតក្នុងរបបទប្បញ្ញត្តិ និងធនធានហិរញ្ញវត្ថុនិងមនុស្ស

ង. លើកសំណើនិងកំណត់អាទិភាពនៃវិធានការដែលត្រូវអនុវត្តដោយអាជ្ញាធរបញ្ញត្តិកម្ម និងភ្នាក់ងារពង្រឹងការអនុវត្តច្បាប់ ដើម្បីដោះស្រាយការគំរាមកំហែងហានិភ័យនិងភាពងាយរងគ្រោះដែលបានរកឃើញ ។

នៅដំណាក់កាលទី២ ការវាយតម្លៃការគំរាមកំហែងហានិភ័យនៃសកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មត្រូវបានអនុវត្តដោយអាជ្ញាធរបញ្ញត្តិកម្មនៃបុគ្គលរាយការណ៍នីមួយៗ នៅថ្នាក់ផ្នែក ឬថ្នាក់ផ្នែករង ដោយផ្តោតទៅលើវិស័យដូចគ្នា ដូចមានចែងនៅចំណុច "ក" ដល់ "ង" ក្នុងការវាយតម្លៃហានិភ័យថ្នាក់ជាតិខាងលើ ។

ចំពោះដំណាក់កាលទី៣ បុគ្គលរាយការណ៍ទាំងអស់ដែលមានកាតព្វកិច្ចត្រូវប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មត្រូវបានតម្រូវឲ្យអនុវត្តការវាយតម្លៃការគំរាមកំហែង និងហានិភ័យនៃសកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មក្នុងប្រតិបត្តិការអាជីវកកម្មរបស់ខ្លួន ។ ជាងនេះទៀតការវាយតម្លៃបែបនេះត្រូវតែបានពិនិត្យនិងធ្វើបច្ចុប្បន្នកម្មប្រចាំគ្រា ។ ការវាយតម្លៃត្រូវផ្តោតទៅលើ ៖

ក. ការរកឲ្យឃើញហានិភ័យ ការគំរាមកំហែងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឬភាពរងគ្រោះនៅគ្រប់ផ្នែកពាក់ព័ន្ធទាំងអស់

ខ. បើអាចអនុវត្តបាន ការងារស្រាវជ្រាវនិងអង្កេត ផ្តល់លទ្ធផលរកឃើញយ៉ាងទូលំទូលាយ និងគួរឲ្យជឿទុកចិត្តបានអំពីប្រភេទសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងចំនួនទឹកប្រាក់ដែលបានប៉ាន់ស្មាន

គ. ការយកចិត្តទុកដាក់ទៅលើការយល់ដឹង និងគំលាតនៃព័ត៌មាន ក្នុងរបបសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

ឃ. លើកសំណើអនុសាសន៍សម្រាប់ដោះស្រាយការខ្វះខាតក្នុងរបបបទប្បញ្ញត្តិ ។

## ២.៤. ភាគីពាក់ព័ន្ធ

អ្នកចូលរួមទាំងអស់ដែលស្ថិតនៅក្រោមរបបប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រូវចូលរួមអនុវត្តយុទ្ធសាស្ត្រដោយឡែកនេះ ។ ជាងនេះទៀត ទស្សនៈ និងការអនុវត្តល្អៗរបស់អ្នកជំនាញការ និងស្ថាប័នខាងក្រៅក៏ត្រូវយកមកបញ្ចូលជាផ្នែកនៃការវាយតម្លៃ។

- មន្ត្រីរាជការដែលមកពីក្រសួង និងស្ថាប័នផ្សេងៗ ដូចជា ធនាគារជាតិនៃកម្ពុជា អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ក្រសួងពាណិជ្ជកម្ម អង្គភាពប្រឆាំងអំពើពុករលួយ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ភ្នាក់ងារអនុវត្តច្បាប់ និងអាជ្ញាធរត្រួតពិនិត្យបុគ្គលរាយការណ៍
- តំណាងពីផ្នែកឯកជន ដោយរួមមានធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ កាស៊ីណូ អាជីវកម្មសេវាសាច់ប្រាក់ និង មុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុផ្សេងទៀត
- ជំនាញការពីវិទ្យាស្ថានស្រាវជ្រាវ ទ្វេភាគី អង្គការអន្តរជាតិនិងចំរុះជាតិសាសន៍ ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្ដីពីការសម្អាតប្រាក់ ការិយាល័យគ្រឿងញៀននិងបទឧក្រិដ្ឋនៃអង្គការសហប្រជាជាតិ និងការិយាល័យជំនួយបច្ចេកទេស រតនាគារសហរដ្ឋអាមេរិក ។

# ៣. ផែនការយុទ្ធសាស្ត្រទី ៣ ៖ ការកសាងសមត្ថភាពរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

## ៣.១. បញ្ហាប្រឈម

ការអនុវត្តមុខងារនិងសមត្ថភាពប្រតិបត្តិការរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវតែបានអភិវឌ្ឍន៍ ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តវិធានការទប់ស្កាត់ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ ធនធានថវិកា និងធនធានមនុស្សគ្រប់គ្រាន់ ត្រូវតែបានផ្តល់ឲ្យអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដើម្បីកសាងរចនាសម្ព័ន្ធមុខងារស្របតាមការអនុវត្តអន្តរជាតិដ៏ប្រសើរបំផុតរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាដោយត្រូវពង្រឹងលទ្ធភាពចូលជាសមាជិកក្រុម Egmont ។ មុខងារសំខាន់របស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា គឺ ១) ទទួល វិភាគ និងបញ្ជូនព័ត៌មានស្តីពីសកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និង ២) សម្របសម្រួលនិងសហប្រតិបត្តិការក្នុងស្រុក និងអន្តរជាតិនៅកម្រិតនយោបាយនិងប្រតិបត្តិការក្នុងការអនុវត្តកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មអន្តរជាតិ ។

ក្នុងរយៈពេលអនុវត្តផែនការយុទ្ធសាស្ត្រ ត្រូវផ្តោតលើការកសាងប្រព័ន្ធគ្រប់គ្រងព័ត៌មានដ៏ទូលំទូលាយមួយ និងសមត្ថភាពបង្កើតរបាយការណ៍ស៊ើបការណ៍និងវិភាគដ៏ទូលំទូលាយជាបន្តបន្ទាប់ ។ នៅពេលនោះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាពិតជាស្ថិតក្នុងស្ថានភាពប្រសើរ ដើម្បីបង្កើនឲ្យកាន់តែទូលំទូលាយនូវព័ត៌មានស្ថិតិ សំដៅបង្កភាពសម្បូរបែបនូវខ្លឹមសារ នៃរបាយការណ៍របស់ខ្លួនទៅឲ្យអ្នកចូលរួមទាំងក្នុងស្រុកនិងអន្តរជាតិ ហើយក្នុងការផ្តល់មតិយោបល់តបវិញទៅបុគ្គលរាយការណ៍តាមរយៈការផ្សព្វផ្សាយប្រចាំគ្រាអំពីប្រធានបទនៅក្នុងនិន្នាការគំរូសិក្សា និងឧប្បត្តិហេតុប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាត្រូវមានបំពាក់សម្ភារៈកាន់តែប្រសើរ ដើម្បីចេញសេចក្តីណែនាំនិងបណ្តុះបណ្តាលគ្រប់គ្រាន់ទៅភ្នាក់ងារបញ្ញត្តិករ និងបុគ្គលរាយការណ៍ស្តីពីការអនុវត្តវិធានការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មប្រកបដោយប្រសិទ្ធភាព ។ សំខាន់ជាងនេះទៀត ត្រូវតាក់តែងប្រធានបទបណ្តុះបណ្តាលឲ្យកាន់តែរឹងមាំដើម្បីលើកកម្ពស់ការយល់ដឹងស្តីពីកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មក្នុងចំណោមអ្នកចូលរួម រួមមានអាជ្ញាធរត្រួតពិនិត្យ បុគ្គលរាយការណ៍ ក្រុមសង្គមស៊ីវិល និងសាធារណជនទូទៅ ។

### ៣.២. គោលបំណង

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាត្រូវមានសមត្ថភាពអនុវត្តមុខងារចំបង និងសម្របសម្រួលយ៉ាងមានប្រសិទ្ធភាពជាមួយអ្នកចូលរួម ។ ការងារនេះតម្រូវឲ្យ ៖

- ផ្តល់ឲ្យបុគ្គលិកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុនូវធនធាន និងសមត្ថភាពគ្រប់គ្រាន់ដើម្បីបំពេញភារកិច្ចប្រកបដោយប្រសិទ្ធភាពឆ្លើយតបនឹងការគំរាមកំហែង និង ហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- ពង្រីក និងសម្រេចឲ្យបានការបង្កើតក្របខ័ណ្ឌត្រួតពិនិត្យលើឯកសារនិងដល់ទីកន្លែងសម្រាប់បុគ្គលរាយការណ៍
- បង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានដ៏ទូលំទូលាយមួយនៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ។ ប្រព័ន្ធនេះនឹងគ្រប់គ្រងព័ត៌មានប្រតិបត្តិការសង្ស័យនិងសាច់ប្រាក់បានយ៉ាងមានប្រសិទ្ធភាព ។ ជាក់ស្តែង ការវិភាគនឹងត្រូវបានធ្វើឡើងយ៉ាងហ្មត់ចត់ ការស៊ើបការណ៍នឹងត្រូវបានបញ្ជូនទៅយ៉ាងឆាប់រហ័សដល់អាជ្ញាធរស៊ើបអង្កេត និងអាជ្ញាធរពង្រឹងការអនុវត្តច្បាប់ ហើយមតិយោបល់ត្រឡប់វិញដ៏មានសារៈប្រយោជន៍នឹងត្រូវបានបញ្ជូនទៅបុគ្គលរាយការណ៍ និងអ្នកចូលរួមផ្សេងទៀត
- បន្តពង្រឹងការអនុវត្តទម្រង់រាយការណ៍ប្រតិបត្តិការជាស្តង់ដារ សម្រាប់របាយការណ៍ប្រតិបត្តិការសង្ស័យនិងប្រតិបត្តិការសាច់ប្រាក់សម្រាប់បុគ្គលរាយការណ៍ទាំងអស់ ។ ដោយមានប្រព័ន្ធអេឡិចត្រូនិកនៅនឹងកន្លែង អាចឲ្យបុគ្គលរាយការណ៍ទាំងអស់រាយការណ៍យ៉ាងឆាប់រហ័សទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នូវប្រតិបត្តិការសង្ស័យនិងប្រតិបត្តិការសាច់ប្រាក់ និងសម្របសម្រួលការចែករំលែក ព័ត៌មានភ្លាមៗទៅអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ
- ធានាថាបុគ្គលរាយការណ៍ទាំងអស់ទទួលបានការយល់ដឹងដ៏ប្រសើរលើប្រភពនិងផលប៉ះពាល់នៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ហើយចូលរួមប្រឆាំងបទល្មើសសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- ពង្រឹងការបណ្តុះបណ្តាលបុគ្គលិកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ អាជ្ញាធរត្រួតពិនិត្យ ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ និងបុគ្គលរាយការណ៍

- អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ផ្តោតការយកចិត្តទុកដាក់ពិសេសចំពោះការកែលម្អនិងបង្កើតលំដាប់ថ្នាក់នៃស្ថិតិ ដើម្បីឆ្លុះបញ្ចាំងការអនុវត្តកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មឲ្យមានប្រសិទ្ធភាព
- ការលើកកម្ពស់ការចូលរួមពីសាធារណជន តាមរយៈយុទ្ធនាការប្រមូលផ្តុំ ដើម្បីគាំទ្រការអនុវត្តរបបប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងជួយបង្កើនការយល់ដឹង និងចំណេះដឹងសំដៅអភិវឌ្ឍវប្បធម៌ ទប់ស្កាត់ការប្រឆាំងបទល្មើសសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៅក្នុងសង្គម ។

### ៣.៣. វិធានការ

សកម្មភាពត្រូវផ្តោតជាដំបូងទៅលើ អភិបាលកិច្ច រចនាសម្ព័ន្ធ និងការបង្កើតអង្គការចាត់តាំងរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ។ បន្ទាប់មកត្រូវចាត់វិធានការជាបន្តបន្ទាប់ដើម្បីកសាងសមត្ថភាពអនុវត្តប្រតិបត្តិការរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដោយត្រូវ ៖

- បង្កើតការដឹកនាំជាយុទ្ធសាស្ត្រសម្រាប់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដែលត្រូវរាប់បញ្ចូលការបង្កើតផែនការច្បាស់លាស់ ដូចជា តម្រូវការធនធាន រចនាសម្ព័ន្ធ និងបច្ចេកវិទ្យាព័ត៌មាន ។ អភិបាលកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវតែបានបង្កើតឡើងឲ្យបានល្អ ដើម្បីឲ្យតួនាទីរបស់អង្គភាពនៅក្នុងរបបប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មត្រូវបានកំណត់និយមន័យបាន ។ សំខាន់ជាងនេះទៀត សិទ្ធិអំណាចនិងស្វ័យភាពរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ក្នុងការអនុវត្តមុខងាររបស់ខ្លួនត្រូវតែពុំមានការជ្រៀតជ្រែកពីសមាជិកក្រុមប្រឹក្សាភិបាល និងអ្នកពាក់ព័ន្ធរបស់រដ្ឋាភិបាលផ្សេងទៀតនៅក្នុងរបបប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បង្កើតក្រមប្រតិបត្តិនិងសំណុំ បទប្បញ្ញត្តិ នីតិវិធី និងសេចក្តីណែនាំ សម្រាប់បុគ្គលិកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- ជ្រើសតាំងបុគ្គលិកបន្ថែមសម្រាប់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងផ្តល់ឱកាសឲ្យទទួលការបណ្តុះបណ្តាលដើម្បីសម្រេចបានមុខជំនាញ និងទទួលបានការយល់ដឹងអំពីបច្ចេកទេសគ្រប់គ្រង វិភាគ និងបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យនិងប្រតិបត្តិការសាច់ប្រាក់ ដើម្បីបន្ថែមតម្លៃ និងបង្កើតរបាយការណ៍ស៊ើបការណ៍ដែលមានសារៈប្រយោជន៍ ។

- បញ្ចប់ប្រព័ន្ធព័ត៌មានគ្រប់គ្រង ដើម្បីកំណត់ស្តង់ដារនៃព័ត៌មានដែលត្រូវរាយការណ៍ពីបុគ្គលរាយការណ៍ និងពង្រឹងសមត្ថភាពដំណើរការវិភាគនិងបង្កើតទិន្នន័យស្ថិតិដែលទាក់ទងនឹងក្របខ័ណ្ឌប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- ផ្តល់សេចក្តីណែនាំចំពោះបុគ្គលរាយការណ៍ស្តីពីកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលរួមគ្នាជាមួយបញ្ញត្តិករ និងបុគ្គលរាយការណ៍ពាក់ព័ន្ធដើម្បីពង្រឹងសមត្ថភាពអនុវត្តវិធានការទប់ស្កាត់ និងកែលម្អការរុករកព្រមជាមួយគុណភាពនៃរបាយការណ៍ស្តីពីសកម្មភាពជាសក្តានុពល នៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលត្រូវបានសង្ស័យ
- មានកម្មវិធីបន្តបន្ទាប់ដើម្បីលើកកម្ពស់ការយល់ដឹងរបស់សាធារណជន អំពីកិច្ចខំប្រឹងប្រែងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់ប្រទេសកម្ពុជា សំដៅបំពេញកាតព្វកិច្ចជាអន្តរជាតិ និងការពារសុចរិតភាព និងស្ថិរភាពនៃប្រព័ន្ធហិរញ្ញវត្ថុក្នុងការគាំទ្រកំណើនសេដ្ឋកិច្ចដែលមាននិរន្តរភាពដើម្បីបង្កើតកម្រិតប្រាក់ចំណូលជាតិ
- បង្កើតពិធីសារ និងទំនាក់ទំនងជាមួយអាជ្ញាធរត្រួតពិនិត្យ និងអង្គភាពពង្រឹងការអនុវត្តច្បាប់ក្នុងស្រុកដើម្បីអនុញ្ញាតឲ្យបញ្ជូនដោយស្ម័គ្រចិត្តនូវរបាយការណ៍ស៊ើបការណ៍របស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ។ កិច្ចសម្របសម្រួលនេះក៏ត្រូវអនុញ្ញាតឲ្យបញ្ជូនសំណើដែលរៀបចំត្រឹមត្រូវទៅអាជ្ញាធរត្រួតពិនិត្យ និងភ្នាក់ងារពង្រឹងការអនុវត្តច្បាប់សម្រាប់ផ្តល់ព័ត៌មានបន្ថែម ដើម្បីពង្រឹងនិងធ្វើឲ្យស៊ីជម្រៅនូវការវិភាគរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងសំដៅបង្កើតរបាយ-ការណ៍ស៊ើបការណ៍ និងព័ត៌មានដ៏ល្អប្រសើរសម្រាប់ការបញ្ជូនទៅអ្នកចូលរួមទាំងនេះ
- បង្កើតពិធីសារ និងទំនាក់ទំនង ដើម្បីអនុញ្ញាតឲ្យចូលយកព័ត៌មានដែលបានកាន់កាប់និងការពារដោយបុគ្គលរាយការណ៍ (បន្ថែមលើរបាយការណ៍ប្រតិបត្តិការសង្ស័យនិងប្រតិបត្តិការសាច់ប្រាក់) និង ភ្នាក់ងាររដ្ឋាភិបាលសម្រាប់គោលបំណងអនុវត្តមុខងារស្របច្បាប់របស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ។

### ៣.៤. ភាគីពាក់ព័ន្ធ

អគ្គសវនកម្មជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា គណៈកម្មការមូលបត្រកម្ពុជា ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងពាណិជ្ជកម្ម អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រុមប្រឹក្សា

គណនេយ្យជាតិ ក្រសួងអប់រំយុវជននិងកីឡា បុគ្គលរាយការណ៍ អាជ្ញាធរក្នុងស្រុក សកលវិទ្យាល័យ សាលារៀន ប្រព័ន្ធឃោសនានិង សាធារណជន ។ អង្គការពហុជាតិ និងអន្តរជាតិ ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ ការិយាល័យអង្គការសហប្រជាជាតិសម្រាប់ត្រួតពិនិត្យគ្រឿងញៀននិងបទឧក្រិដ្ឋ និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុអន្តរជាតិផ្សេងទៀត ។

## ៤. ផែនការយុទ្ធសាស្ត្រទី ៤៖ សុខដុមនីយកម្មច្បាប់ និងការបង្កើតនីតិវិធីបទប្បញ្ញត្តច្បាស់លាស់

### ៤.១. បញ្ហាប្រឈម

របាយការណ៍វាយតម្លៃអញ្ញមញ្ញនៅឆ្នាំ២០០៧ បានរកឃើញចំណុចខ្វះខាតក្នុងក្របខ័ណ្ឌច្បាប់ និង រចនាសម្ព័ន្ធបទប្បញ្ញត្តិដែលគ្រប់គ្រងរបបប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់ប្រទេសកម្ពុជា ។ សមមាត្រដ៏ធំមួយនៃជំហានសកម្មភាពដែលបានតម្រូវដោយក្រុមការងារហិរញ្ញវត្ថុក្រុមត្រួតពិនិត្យអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ និងដំណើរការពង្រឹងការតាមដានរបស់ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់តម្រូវឲ្យមានវិសោធនកម្មនិងសុខដុមនីយកម្មច្បាប់ពាក់ព័ន្ធ ដើម្បីប្រតិបត្តិតាមអនុសាសន៍របស់ក្រុមការងារហិរញ្ញវត្ថុ ។ បន្ថែមលើនេះទៀត នៅមានគម្លាតក្នុងរបបបទប្បញ្ញត្តិដែលរួមមាន ៖

- ពុំទាន់មានទម្រង់ស្តង់ដារសម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ និង បុគ្គលរាយការណ៍ផ្សេងទៀត ដូចជា កាស៊ីណូ ការិយាល័យប្តូរប្រាក់ និងមុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុ ដើម្បីរាយការណ៍ប្រតិបត្តិការសង្ស័យនិងប្រតិបត្តិការសាច់ប្រាក់
- បទបញ្ញត្តិស្តីពីកាតព្វកិច្ចយកចិត្តទុកដាក់ស្គាល់អតិថិជនចាំបាច់ត្រូវពិនិត្យឡើងវិញ ហើយត្រូវប្រកាន់យកវិធានការកែតម្រូវចំណុចខ្វះខាត ដើម្បីអនុវត្តឲ្យបានតាមស្តង់ដាររបស់ក្រុមការងារហិរញ្ញវត្ថុ ។ ចាំបាច់ត្រូវដាក់ចេញនូវវិធានការ ដែលបានពង្រឹងសម្រាប់អតិថិជននិងប្រតិបត្តិការដែលមានហានិភ័យខ្ពស់ ។ ចាំបាច់ត្រូវកំណត់ដំណើរការច្បាស់លាស់មួយសម្រាប់សម្គាល់អត្តសញ្ញាណអត្ថគាហក និងប្រតិបត្តិការដែលបានអនុវត្តជំនួសតតិយភាគី
- បន្ថែមលើនេះ នៅមានការចាំបាច់ត្រូវពិចារណាអំពីបញ្ហាជុំវិញផលប៉ះពាល់នៃបទប្បញ្ញត្តិទៅលើផ្នែកផ្លូវការ ឬផ្នែកដែលត្រូវបញ្ញត្តិ (Regulated Sectors) ដើម្បីកាត់បន្ថយលទ្ធភាពនៃចលនារបស់ប្រតិបត្តិការទៅវិស័យក្រៅផ្លូវការ ក៏ដូចជាធានាសង្គតភាពជាមួយវិធានការសម្រាប់ពង្រឹង

ការប្រើប្រាស់សេវាហិរញ្ញវត្ថុក្នុងចំណោមអាជីវកម្មខ្នាតតូច និងគ្រួសារដែលមានចំណូលតិច មិនប្រើប្រាស់ធនាគារ ។

## ៤.២. គោលបំណង

បង្កើតក្របខ័ណ្ឌច្បាប់ដែលទំនើបនិងសមស្រប និងប្រព័ន្ធបញ្ញត្តិកម្មដែលមានប្រសិទ្ធភាព ដែលបំពេញគោលបំណងស្វែងរក ទប់ស្កាត់ និងបង្ការភ័យខ្លាចដល់សកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មស្របតាមកាតព្វកិច្ចនៃអនុសញ្ញាអង្គការសហប្រជាជាតិ អនុសាសន៍ក្រុមការងារហិរញ្ញវត្ថុ និងកាតព្វកិច្ចជាសមាជិកក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ ។

## ៤.៣. វិធានការ

ប្រទេសកម្ពុជាត្រូវមានវិធានការជាបន្តបន្ទាប់នេះ ដែលអាចត្រូវបានអនុវត្តបន្តបន្ទាប់គ្នា ឬទន្ទឹមគ្នា អាស្រ័យលើលទ្ធភាពធនធាន និងកម្រិតនៃការសម្របសម្រួលនិងកិច្ចសហប្រតិបត្តិការពីអ្នកចូលរួមទាំងអស់ ៖

ក) ពិនិត្យឡើងវិញ និងសុខដុមនីយកម្ម បន្ថែមទៀតនូវច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ក្រមព្រហ្មទណ្ឌ ការត្រួតពិនិត្យគ្រឿងញៀននិងភេរវកម្ម ដើម្បីធ្វើឲ្យស្របគ្នាជាមួយស្តង់ដារ និងកាតព្វកិច្ចអន្តរជាតិ ។ បទប្បញ្ញត្តិនិងនីតិវិធីអនុវត្តពាក់ព័ន្ធ និងនីតិវិធីផ្សេងទៀត ក៏ត្រូវជាកម្មវត្ថុនៃការពិនិត្យឡើងវិញ និងសុខដុមនីយកម្ម ។ ការធ្វើវិសោធនកម្ម និងការផ្លាស់ប្តូរ បើមានតម្រូវការត្រូវមានការអនុមតិពីរដ្ឋសភា ឬអាជ្ញាធរពាក់ព័ន្ធសម្រាប់ដាក់ឲ្យអនុវត្ត ។ ធាតុផ្សំខាងក្រោមត្រូវបានកំណត់ជាអាទិភាព ៖

- បំភ្លឺពីទស្សនៈខុសក្នុងការសម្អាតប្រាក់ ការដាក់ទោសការសម្អាតប្រាក់ និងភ្ជាប់ទៅសំអាងនៃបទល្មើស
- បំភ្លឺពីទស្សនៈខុសក្នុងហិរញ្ញប្បទានភេរវកម្ម ការដាក់ទោសហិរញ្ញប្បទានភេរវកម្មនិងភ្ជាប់ទៅការសម្អាតប្រាក់
- វិធានការបណ្តោះអាសន្ននិងការរឹបអូសទ្រព្យសកម្ម និងទ្រព្យសម្បត្តិ
- ពិនិត្យឡើងវិញថា តើការដាក់ទណ្ឌកម្មចំពោះការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មដោយមិនរួញរា ឬមានសមមាត្រគ្រប់គ្រាន់ទៅនឹងបទឧក្រិដ្ឋធ្ងន់ធ្ងរសមមូលគ្នានៅប្រទេសកម្ពុជា និង

ប្រៀបធៀបជាមួយទណ្ឌកម្មដែលបានអនុវត្តដោយយុត្តាធិការផ្សេងទៀតសម្រាប់បទល្មើសសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

ខ) ធានាថា បទល្មើសសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មគ្របដណ្តប់គ្រប់ស្ថានភាពទាំងអស់ ដែលបានបង្កើតឡើងតាមអនុសញ្ញាក្រុងវីយ៉ែន និងអនុសញ្ញាប៉ាឡឺម៉ូ និងសេចក្តីសម្រេចអង្គការសហប្រជាជាតិ និងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិដែលពាក់ព័ន្ធ និងអនុសញ្ញាផ្សេង ទៀត ដូចជា ការបំប្លែង ឬការផ្ទេរទ្រព្យសម្បត្តិ ការធ្វើលទ្ធកម្ម ការកាន់កាប់ ឬប្រើប្រាស់ទ្រព្យសម្បត្តិ លំដាប់ថ្នាក់នៃសំអាងបទល្មើស ថាតើបានប្រព្រឹត្តនៅប្រទេសកម្ពុជា ឬទីកន្លែងផ្សេងទៀត ការរត់ពន្ធពាណិជ្ជកម្មជារនុកក្នុងការក្លែងបន្លំទីផ្សារ ។ សិទ្ធិតតិយភាគីត្រូវតែបញ្ជាក់ឲ្យច្បាស់លាស់នៅក្នុងច្បាប់នេះ ។

គ) ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវតែបញ្ជាក់ឲ្យច្បាស់លាស់នូវសក្តានុពលសម្រាប់ការប្រើប្រាស់ក្នុងដំណើរការដាច់ដោយឡែក (Ex-parte process) នៅពេលគ្រប់គ្រងបទល្មើសសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

ឃ) ពិនិត្យឡើងវិញ និងបង្កើតយន្តការរឹបអូស បង្កក និងឃាត់ទុកទ្រព្យសកម្ម រួមមានផលនៃបទល្មើស និងផលទាក់ទងនឹងបទល្មើសសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៅក្នុងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងក្រមនីតិវិធីព្រហ្មទណ្ឌឲ្យបានច្បាស់លាស់ ។ ផ្តល់ភាពច្បាស់លាស់ចំពោះការឃាត់ទុក និងការបង្កកទ្រព្យសកម្ម ជាពិសេស ជាក់ស្តែងនៅពេលមានការអំពាវនាវឲ្យជំរុញល្បឿននៃសកម្មភាពដោយគ្មានការពន្យារពេល ។ ចាំបាច់ត្រូវមានទំនាក់ទំនង និងសេចក្តីណែនាំ ដ៏ល្អប្រសើរចំពោះបុគ្គលរាយការណ៍អំពីការបង្កកមូលនិធិដោយគ្មានការពន្យារពេល ទន្ទឹមនេះ ត្រូវមានទណ្ឌកម្ម សមស្របសម្រាប់ការខកខានមិនបានអនុវត្ត ។

ង) តាក់តែង និងផ្សព្វផ្សាយ តាមរយៈដំណើរការទំនាក់ទំនងនិងពិភាក្សាក្នុងចំណោមអ្នកចូលរួមនូវបទប្បញ្ញត្តិពាក់ព័ន្ធ ចំពោះវិធានការទប់ស្កាត់ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មសម្រាប់គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុ សេវាផ្ទេរប្រាក់តាមអេឡិចត្រូនិក កាស៊ីណូ ភ្នាក់ងារអចលនទ្រព្យមេធាវី គណនេយ្យករ និងមុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុ ផ្សេងទៀត ។

### ៤.៤. ភាគីពាក់ព័ន្ធ

អ្នកចូលរួមសកម្ម រួមមាន អគ្គសវនកម្មជាតិ ក្រុមប្រឹក្សាអ្នកច្បាប់ ស្ថាប័នអយ្យការ គណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម ក្រុមប្រឹក្សាគណនេយ្យជាតិ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធផ្សេងទៀត ដូចជា ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា គណៈកម្មការមូលបត្រកម្ពុជា អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងពាណិជ្ជកម្ម និងអង្គការអន្តរជាតិ ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក អាជ្ញាធរត្រួតពិនិត្យបុគ្គលរាយការណ៍ និងបុគ្គលរាយការណ៍ផ្ទាល់ ។

## ៥. ផែនការយុទ្ធសាស្ត្រទី ៥ ៖ ការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងប្រទេស

### ៥.១. បញ្ហាប្រឈម

កិច្ចសហប្រតិបត្តិការ ការសម្របសម្រួល និងការរួបរួមគ្នាមានសារសំខាន់ក្នុងចំណោមអ្នកចូលរួម រាជរដ្ឋាភិបាលក្នុងរបបប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធានការទប់ស្កាត់ ដើម្បីរិះរក ទប់ស្កាត់ និងធ្វើសកម្មភាពប្រឆាំងសកម្មភាពការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

### ៥.២. គោលបំណង

បទបញ្ញត្តិទាំងឡាយត្រូវមាននៅក្នុងច្បាប់ ឬបទប្បញ្ញត្តិ ដើម្បីប្រគល់សិទ្ធអំណាចក្នុងកិច្ចសហប្រតិបត្តិការ ការសម្របសម្រួល និងការរួបរួមគ្នា ក្នុងចំណោមអាជ្ញាធររាជរដ្ឋាភិបាលខុសៗគ្នា ក្នុងរបបប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មដែលទទួលភារកិច្ច ត្រួតពិនិត្យពង្រឹងការអនុវត្ត និងអនុវត្តកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ កិច្ចសហប្រតិបត្តិការ ការសម្របសម្រួល និងការរួបរួមគ្នាត្រូវបានចូលរួមដោយស្ថាប័នក្នុងកម្រិតប្រតិបត្តិការផង និងកម្រិតគោលនយោបាយនិងអនុវត្តផង ។

ដោយសារមានតួនាទីជាស្ថាប័នកណ្តាល អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវបានចាត់តាំងនិងទទួលស្គាល់ថា ជាភ្នាក់ងារដឹកនាំក្នុងការអនុវត្តវិធានការ តាមដានការរីកចម្រើននិងរាយការណ៍ប្រចាំគ្រាអំពីការអភិវឌ្ឍក្នុងក្របខ័ណ្ឌប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

## ៥.៣. វិធានការ

- គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវកំណត់អាទិភាពក្នុងការរៀបចំបទប្បញ្ញត្តិ ដើម្បីប្រគល់សិទ្ធអំណាច ក្នុងកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលក្នុងចំណោមអាជ្ញាធររាជរដ្ឋាភិបាលខុសៗគ្នា ក្នុងរបបប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មដែលទទួលភារកិច្ច ត្រួតពិនិត្យ ពង្រឹងការអនុវត្ត និង អនុវត្តកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវបានចាត់តាំងនិងទទួលស្គាល់ថាជាភ្នាក់ងារដឹកនាំសម្រាប់គ្រប់ការខិតខំប្រឹងប្រែងទាំងអស់របស់ប្រទេសកម្ពុជា ដើម្បីសម្រេចបានតាមបទដ្ឋានអន្តរជាតិក្នុងក្របខ័ណ្ឌប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- នៅពេល អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងអ្នកត្រួតពិនិត្យតាមផ្នែកនៃបុគ្គលរាយការណ៍រៀងខ្លួនត្រូវអនុវត្តការត្រួតពិនិត្យប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ក៏ដូចជា នៅពេលបានចាត់តាំងអ្នកត្រួតពិនិត្យតាមផ្នែកហើយនោះ ការទទួលខុសត្រូវរៀងខ្លួន និងការទទួលខុសត្រូវរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវតែកំណត់ឲ្យបានច្បាស់ ។ ប្រការទាំងនេះត្រូវសមស្របតាមការអនុវត្តល្អជាអន្តរជាតិ និងយន្តការសហប្រតិបត្តិការត្រឹមត្រូវ ត្រូវបានបង្កើតឡើង ។ ជាពិសេស ចាំបាច់ត្រូវមានការបំភ្លឺអំពីបញ្ហាជុំវិញការបើកចំហ និងការអនុវត្តទណ្ឌកម្មខាងវិន័យ
- នីតិវិធី សេចក្ដីណែនាំ និងអនុស្សរណៈយោគយល់គ្នាដែលត្រូវបានតម្រូវ រវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងភ្នាក់ងារស៊ើបអង្កេត អង្គភាពពង្រឹងការអនុវត្តច្បាប់ និងស្ថាប័នអយ្យការចាំបាច់ត្រូវតែមាននិងដាក់ឲ្យដំណើរការឲ្យបានរលូន ។ យន្តការល្អៗ សម្រាប់ដៃគូកម្រិតប្រតិបត្តិការនឹងជួយកែលម្អការងារវិភាគរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដោយរួមចំណែកពង្រឹងកម្លាំងក្នុងការស៊ើបអង្កេតបទល្មើសសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មហើយបាននាំទៅរកដំណើរការកាត់ទោសដោយរស់រវើក និងការកំណត់ទោសជាចុងក្រោយចំពោះបទល្មើសទាំងនោះ ឬមានទោសតាមបទឧក្រិដ្ឋជាក់ស្ដែង ។

### ៥.៤. ភាគីពាក់ព័ន្ធ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា គណៈកម្មការមូលបត្រកម្ពុជា ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងពាណិជ្ជកម្ម ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ទីស្ដីការគណៈរដ្ឋមន្ត្រី ស្ថាប័នអយ្យការ អង្គភាពស៊ើបអង្កេតហិរញ្ញវត្ថុកម្ពុជា អង្គភាពប្រឆាំងអំពើពុករលួយ គណៈកម្មាធិការជាតិប្រឆាំងអំពើភេរវកម្ម និងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

## ៦. ផែនការយុទ្ធសាស្ត្រទី ៦ ៖ ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ

### ៦.១. បញ្ហាប្រឈម

ប្រទេសកម្ពុជាត្រូវមានកិច្ចសហប្រតិបត្តិការ ការសម្របសម្រួល និងការរួបរួមគ្នាក្នុងតំបន់និងអន្តរជាតិ ដើម្បីជាយុទ្ធសាស្ត្រប្រឆាំងឧក្រិដ្ឋកម្មមានការចាត់តាំងឆ្លងដែនដែលអាចមានផលប៉ះពាល់ជាអវិជ្ជមានដល់ស្ថិរភាពនិងកំណើនសេដ្ឋកិច្ចជាតិនៅពេលដែលឧក្រិដ្ឋកម្មនេះកំពុងបំផ្លាញសុខមាលភាពនិងស្ថិរភាពសកលលោក ។ ក្នុងនាមជាសមាជិកដែលមានកិត្តិនាម និងគួរឲ្យជឿជាក់របស់សហគមន៍អន្តរជាតិ ប្រទេសកម្ពុជាបានខិតខំពុះពារសហប្រតិបត្តិការ សម្របសម្រួល និង រួបរួមគ្នាដោយខិតខំប្រឹងប្រែង ទាំងទ្វេភាគីនិងពហុភាគីក្នុងការរិះរក ទប់ស្កាត់ និងលុបបំបាត់ឧក្រិដ្ឋកម្មនិងភេរវកម្មឆ្លងដែន ។

ក្នុងការផ្សារភ្ជាប់ជាមួយប្រជាពលរដ្ឋលើសកលលោក ប្រទេសកម្ពុជាសង្ឃឹមថា បានក្លាយជាសមាជិករបស់ក្រុម Egmont ស្របតាមការតម្រូវរបស់ក្រុមការងារហិរញ្ញវត្ថុ និងស្របតាមគោលការណ៍ក្រុម Egmont សម្រាប់ការចែករំលែកព័ត៌មានរវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុអំពីករណីសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

### ៦.២. គោលបំណង

ត្រូវប្រតិបត្តិតាមកាតព្វកិច្ចអន្តរជាតិ ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម អំពីការផ្លាស់ប្តូរព័ត៌មាន ជំនួយអញ្ញមញ្ញផ្នែកច្បាប់ សំណើសុំបង្គក ឃាត់ទុក និងរឹបអូសទ្រព្យសកម្ម ឬផលនៃបទល្មើស និងបត្យាប័ន ។

## ៦.៣. វិធានការ

- បញ្ចប់ការពិភាក្សា និងការពិចារណា អំពីការផ្តល់សច្ចាប័ន អនុសញ្ញាអង្គការសហប្រជាជាតិដែលនៅសេសសល់ ពិធីសារ និងសន្ធិសញ្ញាចាំបាច់ផ្សេងទៀត ស្របតាមកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- ត្រូវចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាជាមួយប្រទេសដែលសមស្របផ្សេងទៀត ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់និងអន្តរជាតិ (ពិសេស អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេស) ក្នុងការគាស់រំលំឧក្រិដ្ឋកម្មឆ្លងដែន ដែលណែនាំដោយលទ្ធផលដែលបានរកឃើញពីការវាយតម្លៃហានិភ័យប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- ត្រូវដាក់ឲ្យអនុវត្ត បើសមស្របនៅក្រោមច្បាប់និងបទបញ្ជាកម្ពុជា នូវបញ្ជីបុគ្គល ឬ អង្គការដែលបានកំណត់ជាភេរវករ ដោយអនុសញ្ញាអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលបរទេស ។ ទន្ទឹមនេះនីតិវិធី និង តួនាទីរបស់អ្នកចូលរួមក្នុងស្រុកនានា ក៏ត្រូវចងក្រងជាឯកសារឲ្យបានត្រឹមត្រូវ
- ត្រូវស្វែងរកការគាំទ្រជំនួយបច្ចេកទេសពី អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេស និងអង្គការអន្តរជាតិដែលមានបទពិសោធន៍អំពីការវិភាគ បញ្ជូន និងរក្សាទុករបាយការណ៍ និងទិន្នន័យ
- ត្រូវលើកកម្ពស់ និងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិព្រមទាំងបង្កើតយន្តការសម្រាប់ចែករំលែកព័ត៌មានអំពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មទាំងទ្វេភាគីនិងអន្តរជាតិ
- ត្រូវធ្វើការជាមួយប្រទេសជិតខាង ដើម្បីពង្រឹងប្រព័ន្ធប្រតិវេទន៍ឆ្លងដែនដើម្បីគ្រប់គ្រងហានិភ័យដែលកើតឡើងពីចលនាសាច់ប្រាក់ច្រើន និងការដឹកជញ្ជូនសាច់ប្រាក់ដោយត្រូវសហប្រតិបត្តិការនិងសម្របសម្រួលជាមួយភ្នាក់ងារគយ និងភ្នាក់ងារពង្រឹងព្រំដែននិងត្រូវបណ្តុះបណ្តាលភ្នាក់ងារគយអំពីគំរូនៃការគំរាមកំហែងនិងហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

## ៦.៤. ភាគីពាក់ព័ន្ធ

រដ្ឋសភា ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា គណៈកម្មការមូលបត្រកម្ពុជា គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេស និងការិយាល័យអង្គការសហប្រជាជាតិសម្រាប់ត្រួតពិនិត្យគ្រឿងញៀននិងបទឧក្រិដ្ឋ ។

## ៧.ផែនការយុទ្ធសាស្ត្រទី ៧ ៖ ការបង្កើនការយល់ដឹងអំពីការប្រឆាំងការសម្អាតប្រាក់និង ហិរញ្ញប្បទានភេរវកម្មសម្រាប់បុគ្គលរាយការណ៍

### ៧.១. បញ្ហាប្រឈម

នៅពេលប្រកាសឲ្យប្រើច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នៅឆ្នាំ២០០៧ បុគ្គលរាយការណ៍ភាគច្រើន ដែលនៅក្រោមរបបប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មមិនទាន់ទទួលព័ត៌មានបានច្បាស់លាស់អំពីកាតព្វកិច្ចរបស់ខ្លួននៅឡើយ ។ ជាលទ្ធផល កម្រិតប្រតិបត្តិតាម តម្រូវការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មត្រូវបានរំពឹងថា ពិតជាមិនបានគ្រប់គ្រាន់ ដែលបានឆ្លុះបញ្ចាំងជាអវិជ្ជមានទៅលើប្រសិទ្ធភាពនៃការខិតខំប្រឹងប្រែងអនុវត្តរបស់ប្រទេសកម្ពុជា ។ ក្នុងការបន្តអនុវត្តការផ្តួចផ្តើមជាយុទ្ធសាស្ត្រទី១ ដល់ទី៤ ចាំបាច់ត្រូវមានកម្មវិធីបន្តមួយទៀតដើម្បីបង្កើនការយល់ដឹងរបស់អ្នកចូលរួមទាំងអស់ ពិសេស បុគ្គលរាយការណ៍ អំពីអ្វីដែលជាកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងអំពីផលប៉ះពាល់ជាអវិជ្ជមានចំពោះសេដ្ឋកិច្ចដែលមិនប្រតិបត្តិតាមតម្រូវការទាំងនេះ ។

### ៧.២. គោលបំណង

អ្នកចូលរួមពាក់ព័ន្ធទាំងអស់នៅក្នុងរាជរដ្ឋាភិបាល ផ្នែកឯកជននិងសាធារណជនភាគច្រើនបានយល់ដឹងអំពីកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មអន្តរជាតិ និង មុខងាររបស់ខ្លួនក្នុងការប្រតិបត្តិតាមតម្រូវការទាំងនេះ ។

### ៧.៣. វិធានការ

- ការបង្កើនការយល់ដឹងត្រូវតែបានអនុវត្តជាបន្តបន្ទាប់ ដោយផ្តើមចេញពីថ្នាក់ដឹកនាំកំពូល ដែលរួមមាន គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងចុះមកក្រោមរហូតដល់សាធារណជន សង្គមស៊ីវិល និងពលរដ្ឋទូទៅ
- អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវរៀបចំសិក្ខាសាលា អំពីការបង្កើនការយល់ដឹងឲ្យបានទៅដល់គោលដៅសម្រាប់គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងភ្នាក់ងាររាជរដ្ឋាភិបាលផ្សេងទៀតដែលមានតួនាទីក្នុងក្របខណ្ឌប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម រួមទាំង ក្រសួង ស្ថាប័នបញ្ញត្តិកម្ម ភ្នាក់ងារ

ពង្រឹងការអនុវត្តច្បាប់ ស្ថាប័នអយ្យការ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអង្គភាពពាក់ព័ន្ធផ្សេងទៀត

- ត្រូវពង្រីកកម្មវិធីយល់ដឹងអំពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ចំពោះបុគ្គលិកត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ស្ថាប័នបញ្ញត្តិកម្មរាជរដ្ឋាភិបាលផ្សេងទៀត និងស្ថាប័នបញ្ញត្តិកម្មខ្លួនឯងរបស់បុគ្គលរាយការណ៍
- ការបង្កើនការយល់ដឹងត្រូវសម្រេចឲ្យបានរហូតដល់បុគ្គលរាយការណ៍គ្រឹះស្ថានហិរញ្ញវត្ថុ និងមុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុ
- ជាចុងក្រោយ កម្មវិធីយល់ដឹងមានគោលដៅសម្រាប់សាធារណជនទូទៅសង្គមស៊ីវិល អ្នកចូលរួមនិងអ្នកកាសែត
- ការបង្កើនការយល់ដឹងមិនមែនជាព្រឹត្តិការណ៍តែម្តងចប់នោះទេ (one-off) និងត្រូវតែបានអនុវត្តតាមពេលវេលាដែលមាននិរន្តភាពសម្រាប់ធ្វើបច្ចុប្បន្នកម្ម បញ្ជូនព័ត៌មាន និងទទួលមតិយោបល់មកវិញពីអ្នកចូលរួម ។

### ៧.៤. ភាគីពាក់ព័ន្ធ

រដ្ឋសភា ក្រុមប្រឹក្សាអ្នកច្បាប់ ស្ថាប័នអយ្យការ គណៈកម្មាធិការជាតិប្រឆាំងអំពើភេរវកម្មអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ភ្នាក់ងាររាជរដ្ឋាភិបាលដូចជា ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា គណៈកម្មការមូលបត្រកម្ពុជា ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិនិងគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម អង្គការអន្តរជាតិ ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក អាជ្ញាធរត្រួតពិនិត្យបុគ្គលរាយការណ៍ និងបុគ្គលរាយការណ៍ផ្ទាល់ ។

## VI. ការអនុវត្ត ការរាយការណ៍ និងបញ្ហាប្រឈម

គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និង អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នឹងបញ្ចប់ការអនុវត្តផែនការសកម្មភាពដូចមាននៅក្នុងតារាងឧបសម្ព័ន្ធ ។ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ក៏ត្រូវមានតួនាទីតាមដានការអនុវត្តសកម្មភាពទាំងឡាយដែលមានបង្ហាញក្នុងយុទ្ធសាស្ត្រជាតិ និងរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំគ្រាអំពីការវិវឌ្ឍនៃផែនការនេះ ។

### ១. ការអនុវត្ត

ការអនុវត្តផែនការសកម្មភាពនឹងត្រូវធ្វើឡើងតាមវិធានការយុទ្ធសាស្ត្រដែលបានដាក់ចុះទាំង ៧ ដែលបានរៀបរាប់ខាងលើ ។ ការអនុវត្តលម្អិតចំពោះផែនការសកម្មភាពមួយចំនួន ទាមទារឲ្យមានការកំណត់តាមរយៈការបង្កើតបទប្បញ្ញត្តិ នីតិវិធី និងពិធីសារផ្សេងទៀត ។ ចំពោះវិធានការមួយចំនួនដែលទាមទារឲ្យមានការអនុវត្តតាមលំដាប់លំដោយ ត្រូវកំណត់អាទិភាព ដើម្បីឲ្យការអនុវត្តវិធានការមានប្រសិទ្ធភាព។

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជានឹងដើរតួនាទីប្រមូលមតិយោបល់ត្រឡប់វិញ (Feedback) ពីគ្រប់ភាគីពាក់ព័ន្ធអំពីវឌ្ឍនភាព និងផលប៉ះពាល់ក្នុងការអនុវត្តវិធានការ ។ មូលហេតុដែលនាំឲ្យមានការពន្យារពេលក្នុងការអនុវត្តវិធានការ ត្រូវកត់ត្រាទុកជាឯកសារហើយត្រូវកែតម្រូវរយៈពេលកំណត់ ។ នៅក្នុងពេលអនុវត្ត ប្រសិនបើចាំបាច់ត្រូវបន្ថែមវិធានការណាមួយ សម្រាប់គាំទ្រការអនុវត្តឲ្យមានប្រសិទ្ធភាព ត្រូវដាក់វិធានការបន្ថែមនេះ ជូនភាគីពាក់ព័ន្ធ ដើម្បីពិភាក្សា និងសម្រេច ។

### ២. ការរាយការណ៍

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាទទួលខុសត្រូវរាយការណ៍អំពីវឌ្ឍនភាព ផលប៉ះពាល់ និងប្រសិទ្ធភាពនៃការអនុវត្តវិធានការយុទ្ធសាស្ត្រ ជូនគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នៅរាល់កិច្ចប្រជុំ ។ របាយការណ៍ប្រចាំគ្រាអំពីវឌ្ឍនភាពនៃការអនុវត្តក្របខ័ណ្ឌប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នឹងត្រូវបោះផ្សាយជាព័ត៌មានជូនបុគ្គលរាយការណ៍ និងសាធារណជនទូទៅ និងត្រូវបានបញ្ចូលក្នុងកម្មវិធីបង្កើនការយល់ដឹង ឲ្យបានទៅដល់តាមគោលដៅរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ។ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាក៏អាចដាក់ជូនរបាយការណ៍វឌ្ឍនភាពនេះ ទៅសហគមន៍អន្តរជាតិស្របតាមការអនុវត្តកាតព្វកិច្ចរបស់កម្ពុជា ។

## ៣. បញ្ហាប្រឈម

ផែនការអនុវត្ត ត្រូវកំណត់ពីឧបសគ្គនានា និងការងារត្រូវបំពេញជាមួយភាគីពាក់ព័ន្ធ ដើម្បីជំនះនូវបញ្ហាប្រឈមទាំងនេះ ។ នៅពេលដែលមិនមានការព្រមព្រៀងក្នុងការអនុវត្តវិធានការណាមួយ បញ្ហានេះត្រូវបញ្ជូនទៅគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដើម្បីពិភាក្សានិងដោះស្រាយ ។

ប្រទេសកម្ពុជានឹងប្រឈមបញ្ហាគន្លឹះពីការខ្វះខាតធនធានមនុស្ស និងហិរញ្ញវត្ថុ ដើម្បីបង្កើនប្រសិទ្ធភាពនៃរបបការប្រឆាំងសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ ជាងនេះទៀត ដំណើរការការនៃការស្វែងរកការឯកភាពនិងកិច្ចព្រមព្រៀងក្នុងចំណោមភាគីពាក់ព័ន្ធ ជាបញ្ហាប្រឈមក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិឲ្យមានប្រសិទ្ធភាព ។ ទោះយ៉ាងណាក៏ដោយ ការកើនឡើងនៃការយល់ដឹងអំពីកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់ភាគីពាក់ព័ន្ធ នឹងធ្វើឲ្យកម្ពុជាអាចដោះស្រាយបានបញ្ហាប្រឈមទាំងនេះ និងសម្រេចបានគោលដៅកំណើនសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រ ។

## VII. ឧបសម្ព័ន្ធ

### ផែនការសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មឆ្នាំ ២០១៣-២០១៧

| បញ្ហាអាទិភាព | សកម្មភាព | លទ្ធផល | រយៈពេលបញ្ចប់ | ភ្នាក់ងារអនុវត្ត | ដៃគូ | ប្រភពធនធាន |
|---|---|---|---|---|---|---|
| **យុទ្ធសាស្ត្រទី ១ ៖ ការងារគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម (NCC)** | | | | | | |
| ក. កិច្ចសម្របសម្រួលថ្នាក់ជាតិមានកម្រិត | តាមរយៈអនុក្រឹត្យ ខែមេសា ឆ្នាំ២០១២ រដ្ឋាភិបាលបានបង្កើត NCC ដើម្បីអាចធ្វើសហប្រតិបត្តិការ និង សម្របសម្រួលគោលនយោបាយ ក្នុងចំណោមអាជ្ញាធរមានសមត្ថកិច្ច ។ ជំហានបន្ទាប់ គឺត្រូវដំណើរការការងារ NCC ។ | យល់ព្រមលើពេលវេលាប្រជុំ ដើម្បីបង្កើតកម្មវិធីការងាររយៈពេលមធ្យម និងប្រចាំឆ្នាំ ជាមួយនឹងការកំណត់អំពីលទ្ធផលសម្រេចបានគោលដៅទូទៅនៃយុទ្ធសាស្ត្រជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ | ខែមករា ឆ្នាំ២០១៣ | MEF, NBC, SECC, MOI, MOJ, MoFA, CM, NCTC, CAFIU, ACU, CUSTOM | WB, IMF, ADB, APG | NBC |
| ខ. ផែនការសកម្មភាពដោយមានកម្មវិធីអនុវត្ត | ត្រូវបញ្ចប់ផែនការសកម្មភាព និង តាមដានការអនុវត្ត ដើម្បីធានាថា អ្នកចូលរួមម្នាក់ៗ អនុវត្តតាមសកម្មភាពនៅក្នុងយុទ្ធសាស្ត្រជាតិ។ | របាយការណ៍ពីអ្នកចូលរួមម្នាក់ៗ ស្តីពីការអនុវត្តសកម្មភាព ។ | ផែនការសកម្មភាព ៖ ខែមករា ឆ្នាំ២០១៣ របាយការណ៍៖ ជាប្រចាំ | ដូចខាងលើ | ដូចខាងលើ | ភ្នាក់ងារអនុវត្តនីមួយៗ |

| | | | | | | |
|---|---|---|---|---|---|---|
| គ.កង្វះខាតនៃភាពច្បាស់លាស់អំពីភាពបន្ទាន់និងអាណត្តិនៃការធ្វើវិសោធនកម្មច្បាប់ និងប្រកាសស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម | ត្រូវអនុវត្តការងារឆ្ពោះទៅការព្រមព្រៀងស្តីពីការផ្លាស់ប្តូរ បើមានច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ក្រមព្រហ្មទណ្ឌនិងឧបករណ៍គតិយុត្តិផ្សេងៗ ដើម្បីពង្រឹងបទប្បញ្ញត្តិដែលអនុញ្ញាតឲ្យបង្កកទ្រព្យសម្បត្តិរឹបអូស បត្យាប័ន និង ជំនួយផ្លូវច្បាប់អញ្ញមញ្ញ ផ្លាស់ប្តូរព័ត៌មានស្របតាមតម្រូវការរបស់បទដ្ឋាន FATF និង UNSCR ។ | អនុម័តវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ អនុម័តច្បាប់ និងបទប្បញ្ញត្តិអនុវត្តរបបប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម | ផ្លាស់ប្តូរត្រឹមខែធ្នូ ឆ្នាំ២០១៤ ។ ច្បាប់ និង បទ-ប្បញ្ញត្តិថ្មី ត្រឹមពាក់កណ្តាល ឆ្នាំ២០១៣ | ដូចខាងលើ | ដូចខាងលើ | ដូចខាងលើ |
| ឃ. បុគ្គលរាយការណ៍ និងអាជ្ញាធរត្រួតពិនិត្យ ទាំងអស់មិនត្រូវបានសម្គាល់អត្តសញ្ញាណទាំងអស់ទេ | ត្រូវបញ្ចប់ការសម្គាល់អត្តសញ្ញាណបុគ្គលរាយការណ៍ទាំងអស់ និងអាជ្ញាធរត្រួតពិនិត្យរបស់ពួកគេ ចំពោះតម្រូវការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ ពង្រីកការគ្របដណ្តប់ដល់ធនាគារជាតិនៃកម្ពុជា ។ | ស.ហ.ក អាចធ្វើសកម្មភាពរួមគ្នាជាមួយបុគ្គលរាយការណ៍និង អាជ្ញាធរត្រួតពិនិត្យរបស់ពួកគេអំពីការអនុវត្តវិធានការទប់ស្កាត់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនិងអនុវត្តការវាយតម្លៃការប្រតិបត្តិតាម ។ | ការសម្គាល់អត្តសញ្ញាណ ត្រឹមខែ កុម្ភៈ ឆ្នាំ២០១៣ | ដូចខាងលើ រួមជាមួយបុគ្គលរាយ-ការណ៍ | មិនមាន អនុវត្ត | NBC, CAFIU |

| | | | | | | |
|---|---|---|---|---|---|---|
| យុទ្ធសាស្ត្រ ទី២ ៖ ការវាយតម្លៃការគំរាមកំហែងនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម | | | | | | |
| **ពុំមានព័ត៌មានជឿទុកចិត្ត ស្តីពីបច្ចេកទេសសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការប៉ាន់ស្មានពីទំហំសកម្មភាពនេះ នៅប្រទេសកម្ពុជា ។** | <u>ដំណាក់កាលទី១:</u> ត្រូវបង្កើតក្រុមការងារអន្តរភ្នាក់ងាររួមគ្នា ដើម្បីព្រមព្រៀងអំពីវិធីសាស្ត្រអនុវត្តការវាយតម្លៃថ្នាក់ជាតិនូវហានិភ័យនិងការគំរាមកំហែងនៃសកម្មភាពសម្អាតប្រាក់និងហិរញ្ញប្ប-ទានភេរវកម្មក្នុងប្រទេសកម្ពុជា ។ | - ហានិភ័យ ការគំរាមកំហែង ឬភាពងាយរងគ្រោះនៃការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្មទូទាំងវិស័យពាក់ព័ន្ធទាំងអស់និងបុគ្គលរាយការណ៍នីមួយៗ<br>- ការវាយតម្លៃនឹងបង្ហាញចំណេះដឹងនិងគំលាតព័ត៌មានយ៉ាងច្បាស់លាស់នៅក្នុងរបបប្រឆាំងការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម | ដំណាក់ទី១ ត្រឹម ខែមិនា ឆ្នាំ២០១៣ | NBC, CAFIU, CUSTOM អាជ្ញាធរត្រួតពិនិត្យ និង REs | WB, IMF, ADB, APG | NBC, CAFIU, អាជ្ញាធរត្រួតពិនិត្យ និង REs |
| | <u>ដំណាក់កាលទី២:</u> អាជ្ញាធរត្រួតពិនិត្យត្រូវវាយតម្លៃហានិភ័យនិងការគំរាមកំហែងនៃសកម្មភាពសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មមកលើបុគ្គលរាយការណ៍តាមវិស័យ ឬ អនុវិស័យនីមួយ ។ | - ត្រូវមានអនុសាសន៍សម្រាប់ដោះស្រាយការខ្វះខាតនៅក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិនិងតម្រូវការធនធានមនុស្ស និងហិរញ្ញវត្ថុបន្ថែមនៅថ្នាក់ជាតិផ្នែកច្បាប់និងកម្រិតបុគ្គល រាយការណ៍នីមួយៗនិង | ដំណាក់ទី២ ត្រឹម ខែមិថុនា ឆ្នាំ២០១៣ | | | |
| | <u>ដំណាក់កាលទី៣:</u> បុគ្គលរាយការណ៍ | - សម្រេចឲ្យបានការអនុវត្តផ្អែកលើ | ដំណាក់ទី៣ | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | ទាំងអស់ត្រូវបានតម្រូវឲ្យវាយតម្លៃហានិភ័យ និងការគំរាមកំហែងនៃសកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៅក្នុងប្រតិបត្តិការអាជីវកម្មរបស់ខ្លួន ។ | ហានិភ័យនិងការកំណត់អាទិភាពនៃវិធានការទប់ស្កាត់ | ត្រឹម ខែកញ្ញា ឆ្នាំ២០១៣ ត្រូវអនុវត្តជាប្រចាំនូវវិធានការតាមដានផ្សេងទៀត | | | |
| យុទ្ធសាស្ត្រទី ៣ ៖ ការកសាងសមត្ថភាពរបស់ស.ហ.ក | | | | | | |
| **ការកំណត់មុខងារនិងសមត្ថភាពប្រតិបត្តិការរបស់ ស.ហ.ក នៅមិនទាន់មានការរីកចម្រើនដែលជះឥទ្ធិពលដល់ប្រសិទ្ធភាពនៃការអនុវត្តវិធានការទប់ស្កាត់ការសម្អាតប្រាក់/ ហិរញ្ញប្បទានភេរវកម្មរបស់ប្រទេសកម្ពុជា** | - ត្រូវបង្កើតទិសដៅជាយុទ្ធសាស្ត្ររបស់ស.ហ.ក តាមរយៈផែនការច្បាស់លាស់ជាមួយតម្រូវការប្រភពធនធាន និងបច្ចេកវិទ្យាព័ត៌មាន ។ កំណត់ឲ្យបានច្បាស់លាស់នូវអភិបាលកិច្ចនិងរចនាសម្ព័ន្ធ ចាត់តាំង ដោយផ្អែកលើតួនាទីរបស់ ស.ហ.ក នៅក្នុងរបបប្រឆាំងការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម | ស.ហ.ក មានស្វ័យភាពនិងសិទ្ធិអំណាចពេញលេញក្នុងការបំពេញមុខងារនិងកាតព្វកិច្ចរបស់ខ្លួន ។ | ខែកុម្ភៈ ឆ្នាំ២០១៣ | NCC | WB, IMF, ADB, APG and Egmont | NBC |
| | - ត្រូវចាត់តាំងបុគ្គលិកបន្ថែមសម្រាប់ ស.ហ.ក និងផ្តល់ឱកាសបណ្តុះបណ្តាល | ស.ហ.ក អាចអនុវត្តភារកិច្ចជាអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបានពេញលេញ | ផ្តល់បុគ្គលិកបន្ថែមត្រឹមខែ | CAFIU | WB, IMF, ADB, APG | NBC |

| | | | | | | |
|---|---|---|---|---|---|---|
| | ដើម្បីទទួលបានជំនាញ និងការយល់ដឹងស៊ីជម្រៅពីប្រតិបត្តិការអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ។ ដាក់ឲ្យប្រើប្រាស់ក្រមសីលធម៌ បទប្បញ្ញត្តិ នីតិវិធី និង សេចក្តីណែនាំសម្រាប់បុគ្គលិក ស.ហ.ក ។ | ស្របតាមការអនុវត្តដ៏ល្អប្រសើររបស់អន្តរជាតិ ។ | មករា ឆ្នាំ២០១៣ មានសមត្ថភាពពេញលេញ ត្រឹមឆ្នាំ ២០១៧ | | and Egmont | |
| | - ត្រូវបញ្ចប់ការងារប្រព័ន្ធព័ត៌មានគ្រប់គ្រងដើម្បីមានបទដ្ឋានរាយការណ៍ព័ត៌មានពីបុគ្គលរាយការណ៍និងពង្រឹងសមត្ថភាពដំណើរការវិភាគនិងបង្កើតទិន្នន័យស្ថិតិពាក់ព័ន្ធនឹងក្របខ័ណ្ឌការងារប្រឆាំងការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម ។ | មានតម្រូវរបាយការណ៍ជាបទដ្ឋានសម្រាប់របាយការណ៍សង្ស័យនិងសាច់ប្រាក់ ។ បានចែករំលែកព័ត៌មានភ្លាមៗក្នុងចំណោម អាជ្ញាធរមានសមត្ថកិច្ច ។ | បង្កើតឡើងត្រឹមខែមិថុនា ឆ្នាំ២០១៣ កែលម្អការផ្លាស់ប្តូរព័ត៌មាន ត្រឹម ដំណាច់ឆ្នាំ២០១៧ | CAFIU. អាជ្ញាធរត្រួតពិនិត្យ | WB, IMF, APG, Egmont, អ្នកផ្តល់ជំនួយផ្សេងៗ | NBC, អាជ្ញាធរត្រួតពិនិត្យ |
| | -ផ្តល់ការណែនាំដល់បុគ្គលរាយការណ៍អំពីកាតព្វកិច្ច ប្រឆាំងការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម ។ ត្រូវបង្កើតរួមជាមួយ អាជ្ញាធរត្រួតពិនិត្យពាក់ព័ន្ធ និងបុគ្គលរាយការណ៍នូវកម្មវិធីបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពអនុវត្ត | ត្រូវអនុវត្តវិធានការទប់ស្កាត់ឲ្យមានប្រសិទ្ធភាព និងរបាយការណ៍សង្ស័យ/សាច់ប្រាក់ត្រូវមានគុណភាពខ្ពស់ ដើម្បីជម្រុញការរុករក និងស៊ើបអង្កេតសកម្មភាពខុសច្បាប់ ។ | ដំណាច់ ឆ្នាំ ២០១៣ | CAFIU, អាជ្ញាធរត្រួតពិនិត្យ, REs | ដូចខាងលើ | NBC, អាជ្ញាធរត្រួតពិនិត្យ, REs |

| | | | | | | |
|---|---|---|---|---|---|---|
| | វិធានការទប់ស្កាត់ និងកែលម្អការរុករក ព្រមទាំងគុណភាពរបាយការណ៍ សង្ស័យ /សាច់ប្រាក់<br><br>- ត្រូវបង្កើតពិធីសារនិងការជួបផ្ទាល់ ជាមួយអាជ្ញាធរត្រួតពិនិត្យ និងអង្គភាព អនុវត្តច្បាប់ ដើម្បីអាចបញ្ជូនរបាយ ការណ៍ស៊ើបការណ៍របស់ស.ហ.ក ។ | ត្រូវផ្តល់របាយការណ៍ស៊ើបការណ៍ និង ការឆ្លើយតបឲ្យមានប្រសិទ្ធភាព។ | ដំណាច់ ឆ្នាំ២០១៤ | CAFIU, MOI, MOJ, CUSTOM | ដូចខាងលើ | NBC, MOI, MOJ |
| យុទ្ធសាស្ត្រទី ៤ ៖ សុខដុមនីយកម្មច្បាប់និងការបង្កើតនីតិវិធីគតិយុត្តិច្បាស់លាស់ | | | | | | |
| ប្រទេសកម្ពុជាមាន ចំណុចខ្វះខាតច្រើន នៅក្នុងក្របខ័ណ្ឌ ច្បាប់ និងរចនា សម្ព័ន្ធបទប្បញ្ញត្តិ ដែលគ្រប់គ្រងលើ របបប្រឆាំងការ សម្អាតប្រាក់/ហិរញ្ញ ប្បទានភេរវកម្ម | - ត្រូវពិនិត្យឡើងវិញ និងបន្តសុខដុម នីយកម្មបន្ថែមនូវច្បាប់ប្រឆាំងការ សម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ក្រមព្រហ្មទណ្ឌ ច្បាប់ត្រួតពិនិត្យគ្រឿង ញៀន ច្បាប់ប្រឆាំងអំពើភេរវកម្ម ច្បាប់ប្រឆាំងអំពើពុករលួយ ដើម្បីឲ្យ ស្របតាមតម្រូវការនិងបទដ្ឋានអន្តរ ជាតិ។ | - និយមន័យពាក់ព័ន្ធទាំងអស់ក្នុងបទ ល្មើសសម្អាតប្រាក់ ការដាក់ទោសសម្អាត ប្រាក់ និងទំនាក់ទំនងជាមួយសំអាងនៃ បទល្មើសបានស្របតាមបទដ្ឋានអន្តរជាតិ<br><br>-និយមន័យទាំងអស់ដែលអនុវត្តបាននៅ ក្នុងបទល្មើសហិរញ្ញប្បទានភេរវកម្ម ការដាក់ទណ្ឌកម្ម និងទំនាក់ទំនងជា មួយការសម្អាតប្រាក់បានស្របតាម បទដ្ឋានអន្តរជាតិ | ខែមិថុនា ឆ្នាំ២០១៣<br><br>ខែមិថុនា ឆ្នាំ២០១៣ | NCC ACU CUSTOM<br><br>NCC | WB, IMF, ADB, APG<br><br>ដូចខាងលើ | រដ្ឋាភិបាល<br><br>រដ្ឋាភិបាល |

| | | | | | | |
|---|---|---|---|---|---|---|
| | - បទប្បញ្ញត្តិ និងនីតិវិធីអនុវត្តត្រូវស្រប តាមការពិនិត្យឡើងវិញនិងសុខដុមនីយកម្ម ។ | - វិធានការបណ្ដោះអាសន្ន និងការរឹបអូសទ្រព្យសកម្មនិងទ្រព្យសម្បត្តិ សម្រាប់បទល្មើសសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្មត្រូវបានអនុម័ត | ខែមីនា ឆ្នាំ២០១៣ | NCC | ដូចខាងលើ | រដ្ឋាភិបាល |
| | - ប្រសិនបើមានការធ្វើវិសោធនកម្ម និងការផ្លាស់ប្ដូរ ត្រូវបញ្ជូនទៅសុំការអនុមតិពីអាជ្ញាធរពាក់ព័ន្ធ ឬពីរដ្ឋសភាជាតិ ។ | - ទណ្ឌកម្មសម្រាប់ការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម មិនរុញរា និងសមាមាត្រមានលក្ខណៈគ្រប់គ្រាន់ ស្មើគ្នា ចំពោះបទល្មើស ធ្ងន់ធ្ងរទាំងនៅក្នុងប្រទេសកម្ពុជា និងរដ្ឋបរទេស។ | ខែមីនា ឆ្នាំ២០១៣ | NCC | ដូចខាងលើ | រដ្ឋាភិបាល |
| | - ត្រូវធានាថាបទល្មើសសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្មគ្របដណ្ដប់គ្រប់ស្ថានភាពនៅក្នុងអនុសញ្ញា Vienna និង Palermo និង អនុសញ្ញា និងសេចក្ដីសម្រេចរបស់អង្គការសហប្រជាជាតិ និងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ។ | - យន្តការច្បាស់លាស់សម្រាប់ការបង្កកឃាត់ទុក និង រឹបអូសទ្រព្យសម្បត្តិ រួមមានផលនៃបទល្មើស ដែលទាក់ទងនឹងបទល្មើសសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម នៅក្នុងច្បាប់ស្ដីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងក្រមនីតិវិធីព្រហ្មទណ្ឌ<br><br>-ក្របខ័ណ្ឌប្រឆាំងការសម្អាតប្រាក់/ | ខែមីនា ឆ្នាំ២០១៣ | NCC | ដូចខាងលើ | រដ្ឋាភិបាល |

| | | | | | | |
|---|---|---|---|---|---|---|
| | - ត្រូវតាក់តែងនិងចេញផ្សាយ បទប្បញ្ញត្តិ សម្រាប់វិធានការទប់ស្កាត់ការប្រឆាំងការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម សម្រាប់ធនាគារនិងគ្រឹះស្ថាន មិនមែនមែនធនាគារនិងមុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុ ។ | ហិរញ្ញប្បទានភេរវកម្មរបស់ប្រទេសកម្ពុជា ត្រូវបានវាយតម្លៃថា ប្រតិបត្តិតាមបទដ្ឋានអន្តរជាតិបានពេញលេញ និងអនុវត្តប្រកបដោយប្រសិទ្ធភាព ។ | ដំណាច់ឆ្នាំ២០១៧ | NCC, CAFIU | ដូចខាងលើ | NBC |
| **យុទ្ធសាស្ត្រទី ៥ ៖ ការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងប្រទេស** | | | | | | |
| **យន្តការសម្រាប់កិច្ចសហប្រតិបត្តិការ ការសម្របសម្រួល និងការរួបរួមគ្នា ក្នុងចំណោមអ្នកចូលរួមក្នុងជួររដ្ឋាភិបាល នៅក្នុងរបបប្រឆាំងការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម មិនទាន់បានដំណើរការជា** | - ត្រូវបង្កើតអាណត្តិ តាមរយៈបទប្បញ្ញត្តិនូវយន្តការសម្រាប់ កិច្ចសហប្រតិបត្តិការ ការសម្របសម្រួល និងការរួបរួមក្នុងចំណោមអាជ្ញាធររដ្ឋាភិបាលផ្សេងៗគ្នានៅក្នុងរបបប្រឆាំងការសម្អាតប្រាក់/ ហិរញ្ញប្បទានភេរវកម្ម ដែលមានភារកិច្ចត្រួតពិនិត្យ បង្ខំ និងអនុវត្តកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម | ចេញផ្សាយបទប្បញ្ញត្តិចំពោះអណត្តិកិច្ចសហប្រតិបត្តិការ ការសម្របសម្រួល និងការរួបរួមគ្នា ក្នុងចំណោមអ្នកចូលរួមប្រឆាំងការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម | ខែកញ្ញា ឆ្នាំ២០១៣ | NCC | WB, IMF, ADB, APG | NBC |
| | - ត្រូវចាត់តាំង និងទទួលស្គាល់ ស.ហ.ក ជាផ្លូវការជាភ្នាក់ងារដឹកនាំ | កំណត់បានតួនាទីដឹកនាំរបស់ស.ហ.ក | ខែកញ្ញា ឆ្នាំ២០១៣ | NCC | ដូចខាងលើ | NBC |

| | | | | | | |
|---|---|---|---|---|---|---|
| ផ្លូវការ | សម្រាប់កិច្ចប្រឹងប្រែងរបស់ប្រទេសកម្ពុជាទាំងអស់ ក្នុងការអនុវត្តតាមបទដ្ឋានអន្តរជាតិក្នុងក្របខ័ណ្ឌប្រឆាំងការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម<br><br>- ត្រូវបញ្ចប់នីតិវិធី សេចក្តីណែនាំ និងអនុស្សរណៈយល់គ្នារវាងស.ហ.ក និងភ្នាក់ងារស៊ើបអង្កេត អង្គភាពអនុវត្តច្បាប់ និងអាជ្ញាធរតុលាការដើម្បីដំណើរការកិច្ចសហប្រតិបត្តិការ ។ | បង្កើតឲ្យមានអនុស្សរណៈយល់គ្នា សេចក្តីណែនាំ និងនីតិវិធី សម្រាប់ដំណើរការយន្តការកិច្ចសហប្រតិបត្តិការដោយរលូន | ខែមករា ឆ្នាំ ២០១៤ | NCC | ដូចខាងលើ | NBC |
| **យុទ្ធសាស្ត្រទី ៦: ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ** | | | | | | |
| យន្តការក្រៅផ្លូវការសម្រាប់កិច្ចសហប្រតិបត្តិការ ការសម្របសម្រួល និងការរួបរួមគ្នាជាមួយដៃគូអន្តរជាតិពាក់ព័ន្ធ ស្តីពីបញ្ហា | - ត្រូវបញ្ចប់ការពិភាក្សានិង ការពិចារណាលើការធ្វើសច្ចាប័នអនុសញ្ញាអង្គការសហប្រជាជាតិ ពិធីសារ សន្ធិសញ្ញាសំខាន់ផ្សេងៗ ដែលនៅសេសសល់ស្របតាមកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់/ ហិរញ្ញប្បទានភេរវកម្ម | - កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការ ការសម្របសម្រួល និងការរួបរួមគ្នាក្នុងតំបន់និងអន្តរជាតិ ដើម្បីសម្រួលដល់វិធានការស្វែងរក និងទប់ស្កាត់បទឧក្រិដ្ឋមានការចាត់តាំងឆ្លងដែន និងរក្សាកំណើននិងស្ថិរភាពសេដ្ឋកិច្ចជាតិ។ | ខែកក្កដា ឆ្នាំ ២០១៣ | NCC | WB, IMF, ADB, APG, Egmont | NBC |

| | | | | | | |
|---|---|---|---|---|---|---|
| ប្រឆាំងការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម | - ត្រូវចុះអនុស្សរណៈយល់គ្នាជាមួយប្រទេសផ្សេងៗ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់និងអន្តរជាតិ (ជាពិសេសអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុអន្តរជាតិ) ក្នុងការបញ្ឈប់បទឧក្រិដ្ឋឆ្លងដែនតាមរយៈលទ្ធផលនៃការវាយតម្លៃហានិភ័យការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម ។<br><br>- បើស្របតាមច្បាប់និងបទប្បញ្ញត្តិកម្ពុជាត្រូវផ្តល់សុពលភាពបញ្ជីបុគ្គលឬអង្គការ ដែលបានកំណត់ជាភេរវករស្របតាមអនុសញ្ញាអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលបរទេស ។<br><br>- ត្រូវជំរុញ និងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងបង្កើតយន្តការផ្លាស់ប្តូរព័ត៌មានសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្មជាទ្វេភាគីនិងអន្តរជាតិ ។ | - ប្រតិបត្តិតាមកាតព្វកិច្ចអន្តរជាតិប្រឆាំងការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្មស្តីពីការផ្លាស់ប្តូរព័ត៌មាន ជំនួយផ្លូវច្បាប់អញ្ញមញ្ញ សំណើសុំបង្កក កាន់កាប់និងរឹបអូសទ្រព្យសម្បត្តិ ឬផលនៃបទឧក្រិដ្ឋ និង បត្យាប័ន ។ | ខែមករា ឆ្នាំ ២០១៤ | NCC | ដូចខាងលើ | NBC |

| | | | | | | |
|---|---|---|---|---|---|---|
| | - ធ្វើការងារជាមួយប្រទេសជិតខាង ដើម្បីពង្រឹងប្រព័ន្ធប្រតិវេទន៍ឆ្លងដែន ដើម្បីគ្រប់គ្រងហានិភ័យពីការចលនា និងដឹកជញ្ជូនសាច់ប្រាក់ច្រើន ។<br><br>- បំពេញតាមតម្រូវការគុណវុឌ្ឍិ សម្រាប់ការចូលជាសមាជិកក្រុម Egmont ។ | - សមាជិកក្រុម Egmont | ខែមករា ឆ្នាំ២០១៩ | CAFIU | Egmont | NBC |

## IIX- ពាក្យកាត់

ACU : អង្គភាពប្រឆាំងអំពើពុករលួយ

ADB : ធនាគារអភិវឌ្ឍន៍អាស៊ី

AML : ការប្រឆាំងការសម្អាតប្រាក់

APG : ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់

CAFIU : អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

CFT : ការប្រឆាំងហិរញ្ញប្បទានភេរវកម្ម

CJ : ក្រុមប្រឹក្សាច្បាប់

CM : ទីស្តីការគណៈរដ្ឋមន្ត្រី

CTR : ប្រតិបត្តិការសាច់ប្រាក់

CUSTOM : អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

DNFBPs : មុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុ

IMF : អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ

MOC : ក្រសួងពាណិជ្ជកម្ម

MEF : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ML : ការសម្អាតប្រាក់

MLTA : ការវាយតម្លៃការគំរាមកំហែងនៃការសម្អាតប្រាក់

MoFA : ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

MOI : ក្រសួងមហាផ្ទៃ

MOJ : ក្រសួងយុត្តិធម៌

MOU : អនុស្សរណៈនៃការយោគយល់គ្នា

MOEYS : ក្រសួងអប់រំយុវជននិងកីឡា

NA : រដ្ឋសភា

NACD : អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

NBC : ធនាគារជាតិនៃកម្ពុជា

NCC : គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

NCTC : គណៈកម្មាធិការជាតិប្រឆាំងអំពើភេរវកម្ម

OTA : ការិយាល័យជំនួយបច្ចេកទេស រតនាគារសហរដ្ឋអាមេរិក

PG : អគ្គព្រះរាជអាជ្ញា

REs : បុគ្គលរាយការណ៍

SECC : គណៈកម្មការមូលបត្រកម្ពុជា

STR : របាយការណ៍ប្រតិបត្តិការណ៍សង្ស័យ

TF : ហិរញ្ញប្បទានភេរវកម្ម

TOR : បែបបទការងារ

UNODC : ការិយាល័យអង្គការសហប្រជាជាតិសម្រាប់ត្រួតពិនិត្យគ្រឿងញៀងនិងបទឧក្រិដ្ឋ

WB : ធនាគារពិភពលោក